ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ២ ត្រីមាសទី២ ឆ្នាំ២០២០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577    (855) 012 912 009

# <u>គតិបណ្ឌិតរដ្ឋបុរសជាតិ</u>

" ស្រឡាញ់គ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក "

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ឆ្នាំ១៩៩៥

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង
- យឹម ណុលសន

និពន្ធនាយក
- អ៊ីវ ចុង

និពន្ធនាយករង
- អ៊ុន វ៉ាល់ឡឺរ៉ូ
- ប៉ិច សុខា

ការិយាល័យនិពន្ធ
- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អ៊ុន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត
- អ៊ុន វ៉ាល់ឡឺរ៉ូ
- រ័ត្ន សណ្តាប់

អ្នកចែកផ្សាយ
- អេង វត្តមុនី
- សំ សំណាង
- សេក វុទ្ធី

ការីកុំព្យូទ័រ
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**

I- វិចារណកថា " សម រង្ស៊ី លើក «ទង់ស» " ១

II- បទអត្ថាធិប្បាយ " តើអរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ ឬអរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា ? " ២-៤

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តៈ
- ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រើប្រាស់សំណង់ ៥-៦
- ២- គោលនយោបាយជាតិស្តីពីដំឡូងមី ៧-១០
- ៣-សាលារៀនជំនាន់ថ្មី ១១-១៣

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ១៤-២២

V- បទវិភាគៈ
- ១- ផលប៉ះពាល់កូវីដ ១៩ លើសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ២៣-២៦
- ២- "ប្រធានាធិបតី Donald Trump ចោតប្រកាន់ប្រទេសចិនដើម្បីរកលេសសម្រាលទំនួលខុសត្រូវការរីករាលដាល Covid-19" ត្រូវឬខុស ? ២៧-២៨
- ៣- ជោគជ័យរបស់សម្តេចតេជោ ក្នុងការការពារកម្ពុជាប្រយុទ្ធទប់ទល់នឹងមេរោគCovid-19 ២៩-៣០

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៣១-៣៣

VII- នាទីវប្បធម៌
- ពន្យល់ពាក្យ "វៃយ " " លម្អ " " កវី " ៣៤
- ស្រាវជ្រាវ : យល់ដឹងអំពីពាក្យ កូសាំងស៊ីន ៣៥-៣៨

VIII- នាទីកំណាព្យ
- នឹកយុទ្ធជនផង ( បទពាក្យ៧ ) ៣៩
- ន័យជីវិត ( បទពាក្យ៧ ) ៣៩

IX- នាទីកំសាន្ត
- រឿងគំនិតវាងវៃ ៤០
- រឿងការគួសមមួយបែប ៤០

X- បង្កងទឹកសាបអូស្រ្តាលី ៤១-៤៣

# សម រង្ស៊ី លើក «ទង់ស»

*ដោយ ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

តាមបណ្តឹងរបស់**សម្តេចតេជោ ហ៊ុន សែន** ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ បន្ទាប់ពី សម រង្ស៊ី បានចោទមួលបង្កាច់តាមទម្លាប់របស់ខ្លួនមកលើ**សម្តេចតេជោ** ពាក់ព័ន្ធនឹងមរណភាពឧត្តមសេនីយ៍ ហុក ឡង់ឌី ចៅក្រមស៊ើបសួរនៃតុលាការព្រហ្មទណ្ឌ ទីក្រុងប៉ារីសនៃប្រទេសបារាំង ក្រោយពីបានពិនិត្យនិងឃើញមានតម្រុយភស្តុតាងធ្ងន់ធ្ងរ ឬស៊ីចង្វាក់ដែលអាចបញ្ជាក់ថា «បុគ្គល សម រង្ស៊ី បានប្រព្រឹត្តបទល្មើស» ពី «បទបរិហារកេរ្តិ៍ជាសាធារណៈលើបុគ្គល» បានសម្រេចដាក់បុគ្គល សម រង្ស៊ី ឱ្យស្ថិតនៅក្រោមការចោទប្រកាន់ពីបទ «បរិហារកេរ្តិ៍ជាសាធារណៈលើបុគ្គល» នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០កន្លងទៅនេះ។

ចាប់ពីពេលនោះមក យើងឃើញបុគ្គល សម រង្ស៊ី បាត់ម្ញាស់ការ ប្រហែលមិននឹកស្មានថា **សម្តេចតេជោ** ហ៊ានប្តឹងខ្លួនទៅតុលាការប្រទេសបារាំងដែលខ្លួនរស់នៅ បានជាលោតមកប្រតិកម្មស្រែកយ៉ាងក្តែងៗថា **សម្តេចតេជោ ហ៊ុន សែន** ចូលក្នុងអន្ទាក់របស់ខ្លួន និងថាខ្លួនមានឱកាសលើកយកករណីនេះករណីនោះនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយប្រហាររាជរដ្ឋាភិបាល និង**សម្តេចតេជោ**។ ពាក្យពេចន៍បែបវោហារសាស្រ្តទាំងអម្បាលម៉ាននេះ បើគេស្គាល់ចរិតបុគ្គល សម រង្ស៊ី ហើយពុំបានពិចារណាជ្រៅជ្រះអំពីនីតិវិធីតុលាការ ស្តាប់ទៅហាក់ដូចជាខែងរ៉ែងណាស់។ តែដោយឡែកចំពោះអ្នកវិទ្យាសាស្រ្តនយោបាយ អ្នកច្បាប់គេនាំគ្នាសើចព្រោះឃើញទង្វើបុគ្គល សម រង្ស៊ី និយាយមានលក្ខណៈប៉ាតណាប៉ាតណីហាក់ដូចជាភ័យស្លន់ស្លោ ពីព្រោះនីតិវិធីតុលាការ មុននឹងចោទប្រកាន់បទល្មើសអ្វីមួយ តែងឈរជារួមលើគោលការណ៍ធាតុផ្សំបីគឺៈ ទី១_បទល្មើសដែលមានចែងក្នុងច្បាប់ ទី២_ភស្តុតាង និងទី៣_អំពើចេតនាទុច្ចរិតរបស់បុគ្គល។ ក្នុងន័យនេះនីតិវិធីតុលាការចំពោះកម្មវត្ថុបណ្តឹងណាមួយគេដោះស្រាយតែក្នុងរង្វង់កម្មវត្ថុហ្នឹងតែប៉ុណ្ណោះ។ជនជាប់ចោទពុំអាចលើកយកករណីណាផ្សេង ក្រៅពីកម្មវត្ថុដែលបានកំណត់ក្នុងបទល្មើសបានឡើយ។

ករណីបុគ្គល សម រង្ស៊ី ជារឿងក្តីបណ្តឹងមួលបង្កាច់ពាក់ព័ន្ធនឹងមរណភាពឧត្តមសេនីយ៍ ហុក ឡង់ឌី។ បើដូច្នេះ ភស្តុតាងដោះបន្ទុកស្ថិតក្នុងកម្មវត្ថុនេះឯង តុលាការពុំអនុញ្ញាតឱ្យបុគ្គល សម រង្ស៊ី និយាយប៉ប៉ាច់ប៉ប៉ោចពីនេះពីនោះ ចាកប្រធាន ដែលរំខាន ឬពុំបម្រើដល់រឿងក្តីឡើយ។

ចំពោះករណីបុគ្គល សម រង្ស៊ី ដែលលើកយករឿងពីនេះពីនោះមកនិយាយ ផ្ទុយនឹងកម្មវត្ថុបណ្តឹង ដើម្បីចង់បំភាន់មតិជាតិ អន្តរជាតិ និងតុលាការ គឺជាការលើក «ទង់ស» មុននឹងតុលាការព្រហ្មទណ្ឌទីក្រុងប៉ារីសកាត់សេចក្តី។ ដូច្នេះ **សម្តេចតេជោ** បានទទួលយុត្តិធម៌ជាស្វ័យប្រវត្តិរួចទៅហើយ៕

# តើអរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ ឬអរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា?

ប្រជាពលរដ្ឋនីមួយៗដែលប្រមូលផ្តុំគ្នាជាជនជាតិមួយបានលុះត្រាតែមានប្រទេសមួយដែលមានព្រំដែនទឹកដីច្បាស់លាស់ រួមជាមួយនឹងព្រលឹងជនជាតិនោះក្រោមរបបគ្រប់គ្រងមួយដូចគ្នា ប្រពៃណីដូចគ្នា ជំនឿសាសនាដូចគ្នា មានមនោគមវិជ្ជា របៀបរៀបចំសង្គមដូចគ្នា រួមបានជាអរិយធម៌របស់ជនជាតិនោះ។ ប៉ុន្តែអរិយធម៌របស់ជនជាតិនីមួយៗរមែងទទួលឥទ្ធិពលពីប្រទេសដទៃដែលមានកម្លាំងខ្លាំងជាងទើបមានមតិមួយចោទសួរថា **តើអរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ ឬអរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា?**

តាមន័យទូទៅ អរិយធម៌សម្គាល់មែកធាងទាំងឡាយក្នុងសង្គម ដែលមានលក្ខណៈជា ជំនឿ សាសនា សិល្បៈ អក្សរសិល្ប៍ ប្រពៃណី របបគ្រប់គ្រង មនោគមវិជ្ជា សម្រាប់ធ្វើឱ្យរចនាសម្ព័ន្ធសង្គមមានទំនាក់ទំនងទៅវិញទៅមក។

តាមន័យពិសេសអរិយធម៌សម្គាល់ការជឿនលឿននៃប្រទេសនីមួយៗក្នុងវិស័យវប្បធម៌និងសង្គមធម៌ ហើយដែលអាចបន្តជីវិតទៅសម័យកាលខាងមុខទៀត។

**១- អរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរ**

អរិយធម៌ឥណ្ឌាចូលមកកាឡៃអរិយធម៌ខ្មែរ តាមរយៈពលរដ្ឋឥណ្ឌាម្នាក់ដែលមានឈ្មោះថា កៅណ្ឌិន្យ ប្រហែលជានៅពាក់កណ្តាលសតវត្សទី១នៃគ.ស. ក្នុងរជ្ជកាលព្រះនាង សោមា ឬលីវយី ឬនាងនាគសម័យហ្វូណន ទំនាក់ទំនងនេះពុំបញ្ជាក់ថា អរិយធម៌ខ្មែរគឺអរិយធម៌ឥណ្ឌាទេ ព្រោះមតិខ្លះច្រើនភាន់ច្រឡំដោយស្មានថា ឥណ្ឌាជាបុព្វបុរសរបស់ខ្មែរ ឬឥណ្ឌាជាខ្មែរដើម។ តាមពិតមុនឥណ្ឌាចូលមកដល់ប្រទេសខ្មែរសម័យហ្វូណន វត្តមាននៃប្រទេសខ្មែរមានរួចមកហើយ ឯអរិយធម៌ខ្មែរក៏មានរួចហើយដែរ ទ្រទ្រង់នូវរបបគ្រប់គ្រងមួយរបស់ខ្មែរ គឺរបបមាតាធិបតេយ្យ (le régime matriarcal)។ តើអរិយធម៌ឥណ្ឌាកាឡៃអរិយធម៌ខ្មែរដូចម្តេចខ្លះក្នុងវិស័យវប្បធម៌ និងសង្គមធម៌?

**ក- ក្នុងវិស័យវប្បធម៌**

- ឥណ្ឌាបញ្ចូលជំនឿបូជាយញ្ញតាមលទ្ធិវេទ ដូចមានអធិប្បាយក្នុងគម្ពីរវេទទាំងបួនគឺៈ
  + ឫគវេទ : ផ្តល់ជំនឿបន់ស្រន់ទេវតាក្នុងធម្មជាតិ
  + យជុរវេទ : បន់ស្រន់ទេវតាឋានលើ ឱ្យចុះមកជួយមនុស្សដែលទទួលរងគ្រោះដោយអំពើផ្សេងៗ
  + សាមវេទ : ផ្តល់ជំនឿអប់រំមនុស្សឱ្យសិក្សាមន្តអាគមសម្រាប់ការពារខ្លួន ដូចជាក្បាច់គុណ ក្បាច់ដំបង ក្បាច់ក្រពើហា...
  + អាថ៌វេទ : ផ្តល់ជំនឿឱ្យចេះការពារជំងឺផ្សេងៗ ដូចជាស្តោះពិសពស់ ចុក រាគ មួល លើករាសីហេតុដល់មន្តអាគមស្នេហ៍ សម្រាប់ព្យាបាលជំងឺស្នេហា។

ប៉ុន្តែបន្ទាប់ពីសម័យវេទ ខ្មែរបានកាន់សាសនាព្រាហ្មណ៍ដូចឥណ្ឌាដែរ ខ្មែរបានកាន់សាសនាព្រះសិវៈ (ឥសូរ) តាំងពីមុនពាក់កណ្ដាលសតវត្សទី១ រហូតដល់សតវត្សទី១០។ ពីសតវត្សទី១០ ដល់ទី១១ ខ្មែរបានកាន់សាសនាព្រះវិស្ណុឬព្រះនារាយណ៍ព្រោះសាសនានេះជួយមនុស្សច្រើនប្រការឱ្យបានធូរស្បើយពីទុក្ខសោក។ ពីសតវត្សទី១២ ដល់ទី១៤ ខ្មែរបានកាន់ព្រះពុទ្ធសាសនាមហាយាន ចំណែកឯលទ្ធិហីនយានជាឥទ្ធិពលរបស់សៀមព្រោះសៀមបង្ខំខ្មែរឱ្យកាន់ហីនយានតាមឧបាយកលរបស់ព្រះបាទឥន្ទ្រវ្ម័នទី៣គិតយ៉ាងណាឱ្យតែបានសោយរាជ្យ ជាការបញ្ជាក់ថាខ្មែរឋិតនៅក្រោមចំណុះសៀម ហើយចាប់តាំងពីពេលនោះមក សម័យមហានគររបស់ខ្មែរ ត្រូវបានស្រុតចុះឥទ្ធិពលរបស់ខ្លួនមកដល់សម័យបាក់ស្បាត ដើម្បីប្រលោមខ្មែរ ឱ្យចូលក្នុងពូជអំបូរថៃ ជាការងាយស្រួលប្រមូលយកទឹកដីខ្មែរ តាមនយោបាយប្រមូលជនជាតិរបស់ថៃ រៀបចំឡើងដោយហ្លួងវិជិត្រវាទកានដែលមានឈ្មោះថា នយោបាយសមាហរណកម្ម (la politique d’assimilation)។

-ប្រពៃណីរំលាយសពដោយយកសពទៅដុត ហើយរើសយកធាតុមកទុកក្នុងថូមួយ តំណាងព្រលឹងនៃអ្នកស្លាប់ ចំណែកឯការរំលាយសពខ្មែរបុរាណ គឺគេយកសពទៅទុកទីកន្លែងមួយសម្រាប់ឱ្យត្មាតស៊ី ឬបោះក្នុងទឹកឱ្យត្រីស៊ី ឯការកប់ខ្មោចជាឥទ្ធិពលរបស់ចិន។

-ទ្រឹស្ដីគម្ពីរវេទបានចែងថា មនុស្សត្រូវរស់នៅដោយចែកវណ្ណៈ ទើបអាចសម្គាល់មនុស្សល្អឬអាក្រក់។

-ចំពោះភាសានិងអក្សរ ខ្មែរបានទទួលឥទ្ធិពលច្រើនពីឥណ្ឌា ក្នុងករណីដែលខ្មែរខ្វះពាក្យប្រើប្រាស់ដូចជាពាក្យសុខ ទុក្ខ យក្ស សីលធម៌...

នៅមានសាខានៃវប្បធម៌ច្រើនទៀត ក្នុងវិស័យទ្រឹស្ដី ចិត្តគំនិត ដែលឥណ្ឌាកាឡៃវប្បធម៌ខ្មែរ។

**ខ- ក្នុងវិស័យសង្គមធម៌**

សង្គមធម៌សង្កត់ទៅលើទ្រឹស្ដីរបស់សង្គមនិងការរៀបចំសង្គមឱ្យមានទំនាក់ទំនងទៅវិញទៅមកតាំងពីវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច ជីវភាពទូទៅ សន្តិសុខជាដើមៈ

-ក្នុងវិស័យសេដ្ឋកិច្ច ខ្មែរធ្វើកសិកម្ម ប៉ុន្តែគេហាមប្រាមមិនឱ្យសម្លាប់សត្វ ដែលជាបទបញ្ញត្តិក្នុងពុទ្ធសាសនា។

-ក្នុងវិស័យនយោបាយខ្មែរពុំចេះធ្វើនយោបាយទេក្រៅពីគោរពបូជាសាសនាហើយយកសាសនាជំនួសនយោបាយ បើសាសនាពុំត្រូវគ្នា គឺឈប់រាប់អានគ្នារហូតដល់យកសង្គ្រាមផ្ទាល់ខ្លួនដាក់ជាសង្គ្រាមសាសនា។

-ក្នុងវិស័យជីវភាពរស់នៅ ខ្មែរនិយមធ្វើបុណ្យនិងនិយមបួស បួសរួចហើយទើបប្រកបជីវភាព។

-ក្នុងវិស័យសន្តិសុខ ខ្មែរនិយមការសន្តោសតាមបែបពុទ្ធសាសនា ប៉ុន្តែតាមខ្មែរបុរាណ អ្នកប្រព្រឹត្តបទល្មើសត្រូវតែមានទោស ពុំនិយមការសន្តោសទេ។

**២-អរិយធម៌ខ្មែរកាឡៃអរិយធម៌ឥណ្ឌា**

**ក- ក្នុងវិស័យវប្បធម៌**

-ជំនឿបូជាយញ្ញដែលឥណ្ឌាតម្រូវឱ្យអនុវត្តរហូតដល់សម្លាប់ជីវិតមនុស្ស ខ្មែរបានកាឡៃពិធីបូជាយញ្ញនេះ ឱ្យនៅត្រឹមតែការសែនព្រេន និងសម្លាប់ជីវិតសត្វជំនួសវិញ។

-ព្រះឥសូរព្រះវិស្ណុដែលជាព្រះអាទិទេពឥតកំហុសខ្មែរបានកាឡៃឱ្យអាទិទេពទាំងនេះបែរជាមានកំហុសខ្លះក្នុងសាសនារបស់ខ្មែរ តាមរយៈរឿងរាមកេរ្តិ៍ខ្មែរ។

-ព្រះពុទ្ធសាសនានៅស្រុកខ្មែរ មានលក្ខណៈប្លែកគ្នាពីពុទ្ធសាសនានៅឥណ្ឌា និងនៅសិរីលង្កាភាគច្រើននៃអ្នកកាន់ពុទ្ធសាសនាខ្មែរ ច្រើនយកសាសនាជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហាជីវភាព បញ្ហាក្រពះ បញ្ហាសិក្សា ព្រោះនៅជាគ្រហស្ថពិបាករៀនសូត្រ ហើយខ្វះខាតប្រាក់កាសផង ឯខ្លះទៀតអាយុច្រើនហួសពុំមានសិទ្ធិចូលរៀនសូត្រតាមធម្មតា។ ពេលបានបួសរៀន ព្រះសង្ឃមានលទ្ធភាពបង្កើតចំណេះវិជ្ជារហូតដល់បានចេះដឹងច្រើន ហើយក៏លាចាកសិក្ខាបទ ដើម្បីកសាងជីវភាពដូចគេដូចឯង។

-សព្វថ្ងៃនេះការបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនាមានចំនួនកាន់តែច្រើនឡើងហើយមានព្រះសង្ឃខ្លះបានឆ្លៀតចូលរៀននៅតាមសាកលវិទ្យាល័យរដ្ឋនិងឯកជន លើមុខជំនាញវិទ្យាសាស្ត្រសង្គមដូចជា គ្រប់-គ្រងសេដ្ឋកិច្ចពាណិជ្ជកម្មរដ្ឋបាលសាធារណៈ...។គេសង្កេតឃើញថាភាគតិចណាស់នៃអ្នកកាន់ពុទ្ធសាសនាខ្មែរដែលគោរពតាមឱវាទព្រះពុទ្ធសាសនាទាំងស្រុង។

**ខ- ក្នុងវិស័យសង្គមធម៌**

-ក្នុងផ្នែកនយោបាយ ខ្មែរយល់ថាសាសនាគ្រាន់តែជាឈ្នាន់ដើម្បីទៅកាន់អំណាច ព្រោះខ្មែរយល់នយោបាយពុំច្បាស់លាស់។ លុះបានអំណាចហើយ គេច្រើនយកអំណាចជាឈ្នាន់ស្វែងរកប្រយោជន៍ ហើយប្រយោជន៍ភាគច្រើន ជាប្រយោជន៍ផ្ទាល់ខ្លួន។

-ចំពោះការរស់នៅ ខ្មែរបានកាឡៃវណ្ណៈទាំងបួនរបស់ឥណ្ឌា (ក្សត្រិយៈ ព្រាហ្មណៈ វេស្សៈ សូទ្រៈ) ឲ្យនៅត្រឹមតែវណ្ណៈពីរ គឺអ្នកមាននិងអ្នកក្រ។ វណ្ណៈទាំងពីរនេះអាចរលាយចូលគ្នាបាន ពោលគឺអ្នកក្រខំរកស៊ីទៅជាអ្នកមាន ឯអ្នកមានបើមិនខំរកស៊ីឬមានគ្រោះថ្នាក់ចៃដន្យកើតឡើងដូចជាភ្លើងឆេះផ្ទះ ទ្រព្យសម្បត្តិត្រូវលិចលង់ក្នុងទឹក ពេលទឹកជំនន់ ឬសំពៅ កប៉ាល់លិច អ្នកមានអាចធ្លាក់ខ្លួនទៅជាអ្នកក្រ។

-ក្នុងផ្នែកសេដ្ឋកិច្ចឥណ្ឌាពុំមានលក្ខណៈច្បាស់លាស់ទេ។ឥណ្ឌាសម័យបុរាណច្រើនលក់វត្ថុធាតុដើម ឯខ្មែរក៏ចូលចិត្តលក់វត្ថុធាតុដើមដែរ ពុំសូវប្រសប់ធ្វើឈ្មួញកណ្តាលដូចចិនទេ។

-ក្នុងផ្នែកសង្គមកិច្ចនិងការរៀបចំសង្គមទូទៅ ខ្មែរច្រើនទទួលឥទ្ធិពលអរិយធម៌របស់បស្ចិមប្រទេស។

ជាការសង្កេតទូទៅទំនាក់ទំនងរវាងខ្មែរនិងឥណ្ឌាច្រើនមាននៅក្នុងផ្នែកវប្បធម៌រីឯផ្នែកសង្គមធម៌របស់ឥណ្ឌា ពុំសូវមានឥទ្ធិពលមកលើសង្គមខ្មែរទេ ពីព្រោះឥណ្ឌាពុំសូវយល់ទ្រឹស្តីសង្គម។

ការទទួលឥទ្ធិពលរបស់ប្រទេសដែលមានអរិយធម៌ខ្ពង់ខ្ពស់ជាងជាករណីធម្មតារបស់ប្រទេសទូទៅក្នុងលោក ហើយពុំអាចចាត់ទុកជាភាពអន់ថយ នៃប្រទេសដែលទទួលឥទ្ធិពលពីគេនោះឡើយ សូម្បីតែឥណ្ឌាខ្លួនឯងសោតក៏ទទួលឥទ្ធិពលអរិយធម៌ពីពួកអារ្យ៉ែន(Aryens)ដែលភាគច្រើនមកពីតំបន់សមុទ្រមេឌីទែរ៉ាណេនិងតំបន់មេហ្សូប៉ូតាមីប្រហែលសតវត្សទី១២មុនគ.ស.ហើយនៅសតវត្សទី១៩ឥណ្ឌាធ្លាប់នៅក្រោមអរិយធម៌របស់អង់គ្លេស ឯអង់គ្លេសក៏ធ្លាប់នៅក្រោមអរិយធម៌បារាំង កាលពីសតវត្សទី១១ ជំនាន់ស្តេចបារាំងដែលមាននាមថា Guillaume le Conquérant ។

រួមសេចក្តីមកឥណ្ឌាកាឡៃអរិយធម៌ខ្មែរនិងខ្មែរកាឡៃអរិយធម៌ឥណ្ឌាជាករណីធម្មតារបស់ប្រទេសក្នុងសកលលោកនេះប៉ុន្តែអរិយធម៌ជនជាតិណាមួយដែលមានព្រលឹងរបស់ខ្លួនពុំងាយនឹងទទួលការប្រែប្រួលតាមអរិយធម៌បរទេសបានឡើយ ប៉ុន្តែអរិយធម៌ទន់ខ្សោយត្រូវតែជំនួសដោយអរិយធម៌ខ្លាំងជានិច្ចទប់ទល់ពុំបានវិស័យដូចជាចរន្តទឹកអញ្ចឹង ហើយក៏មិនត្រូវតូចចិត្តនឹងអរិយធម៌ដែលមានកម្លាំងខ្លាំងជាងនោះដែរ។អរិយធម៌ជនជាតិនីមួយៗសុទ្ធសឹងកើតមកពីទំនាក់ទំនងរវាងអរិយធម៌របស់ជនជាតិដទៃទៀតជាដរាប ប៉ុន្តែ ជនជាតិនីមួយៗ រមែងមានអរិយធម៌ពិសេសរបស់ខ្លួន ដែលគេហៅថាព្រលឹងរបស់ជនជាតិនោះ៕

## ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រើប្រាស់សំណង់

សេចក្តីព្រាងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី និងត្រូវបាន ឯកឧត្តមប្រធាន ក.ស.វ. ចាត់ចែងឲ្យក្រុមការងារ ក.ស.វ. ធ្វើការប្រជុំពិនិត្យពិភាក្សានៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ តាមចំណាររបស់ឯកឧត្តម កិត្តិនិតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ការប្រជុំពិនិត្យពិភាក្សាសេចក្តីព្រាងអនុក្រឹត្យទី១ស្តីពីលិខិតអនុញ្ញាតសាងសង់ បានប្រព្រឹត្តទៅអស់រយៈពេលមួយព្រឹកធំ។ ដោយឡែកដោយសារបញ្ហាមេរោគកូវីដ ១៩ ដែលមិនអនុញ្ញាតឲ្យមានការរួមប្រជុំបន្តទៀត ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យទី២ស្តីពីការគ្រប់គ្រងការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធតេលេក្រាម។ ចំណែកឯសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រើប្រាស់សំណង់ ត្រូវបានក្រុមការងារ ក.ស.វ. ប្រជុំពិនិត្យពិភាក្សានៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០។

ជារួមសេចក្តីព្រាងអនុក្រឹត្យទាំងបីនេះ គឺរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃការងារសាងសង់រយៈពេលជាងមួយទសវត្សចុងក្រោយនេះដែលមានសំណង់កាន់តែច្រើនកាន់តែធំកាន់តែខ្ពស់និងកាន់តែស្មុគស្មាញនៅទូទាំងប្រទេស។ ការរៀបចំនេះក៏ដើម្បីឆ្លើយតបជាពិសេសទៅនឹងតម្រូវការរបស់ច្បាប់ស្តីពីសំណង់ដែលត្រូវបានប្រកាសឲ្យប្រើនាពេលកន្លងមកថ្មីៗនេះដោយព្រះរាជក្រមលេខនស/រកម/១១១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ជំពូកទី៨ ចំពោះសេចក្តីពាព្រងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសាង់ ជំពូកទី៤ ចំពោះសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការត្រួតពិនិត្យនិងបញ្ជាក់សំណង់និងជំពូកទី១១ចំពោះសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រើប្រាស់សំណង់។

ក្រុមការងារ ក.ស.វ. បានពិនិត្យជាបឋមលើទិដ្ឋភាពរួម ជាពិសេសលើចំណងជើង។ ជាទូទៅ ចំណងជើងនៃអនុក្រឹត្យក៏ដូចជាចំណងជើងនៃលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែរបើមានការចង្អុលបង្ហាញដោយមាត្រាណាមួយនៃលិខិតបទដ្ឋានគតិយុត្តដែលមានអនុភាពខ្ពស់ជាង ត្រូវសរសេរឲ្យដូចការកំណត់នៅក្នុងមាត្រានៃលិខិតបទដ្ឋានគតិយុត្តនោះ។ ចំពោះសេចក្តីព្រាងអនុក្រឹត្យទាំងបីខាងលើ ការដាក់ចំណងជើង គឺមិនដូចការចង្អុលបង្ហាញនៃមាត្រាណាមួយនៃច្បាប់ស្តីពីសំណង់ឡើយ។ ប៉ុន្តែករណីដាក់ចំណងជើងមិនដូចការកំណត់របស់ច្បាប់ តែក្រសោបខ្លឹមសារច្រើនដូចករណីសេចក្តីព្រាងខាងលើ ធ្លាប់បានអនុវត្តកន្លងមកច្រើនហើយដែរចំពោះក្រសួង ស្ថាប័នមួយចំនួន។

ជារួមក្រុមការងារ ក.ស.វ. បានឯកភាពរក្សាចំណងជើងនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ ដែលដូចគ្នាទៅនឹងចំណងជើងនៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ដែលត្រូវទុកជានិរាករណ៍ នៅពេលអនុក្រឹត្យថ្មីចូលជាធរមាន។ ដោយឡែក ចំណងជើងនៃអនុក្រឹត្យពីរទៀត ដែល

ស្តីពី "ការគ្រប់គ្រងការត្រួតពិនិត្យ" និង "ការគ្រប់គ្រងស្តីពីការប្រើប្រាស់សំណង់" មានលក្ខណៈទូលាយពេក មិនត្រូវនឹងវិសាលភាពនៃអនុក្រឹត្យដែលមានលក្ខណៈបច្ចេកទេសច្រើនដូច្នេះត្រូវកែសម្រួលឬយកតាមមាត្រា ជាក់លាក់ណាមួយនៃច្បាប់ស្តីពីសំណង់។

សេចក្តីព្រាងអនុក្រឹត្យទាំងបីដែលក្រុមការងារ ក.ស.វ. បានពិនិត្យមានការតាក់តែងមូលបទប្រហែល គ្នាស្រង់តែលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងសេចក្តីព្រាងបានសព្វគ្រប់ដូចគ្នា តែប្រការដែលគួរកែលម្អគឺ បន្ទាប់ពីក្រមប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង គប្បីរៀបចំលិខិតបទដ្ឋានឯទៀតទៅតាមលំដាប់ កាលប្បវត្តិ ក្រមតាមក្រម ព្រះរាជក្រឹត្យតាមព្រះរាជក្រឹត្យ អនុក្រឹត្យតាមអនុក្រឹត្យ។

ក្រុមការងារសង្កេតឃើញថា សេចក្តីព្រាងអនុក្រឹត្យទាំងបីនេះ មានវិសាលភាពទូលំទូលាយ មានការ ពាក់ព័ន្ធច្រើន បើមានការឆ្លងអន្តរក្រសួង និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនោះជាការប្រសើរ។ ក្នុងករណី នេះ រូបមន្តបញ្ចប់នៃមូលបទត្រូវកែសម្រួលឲ្យបានសមស្រប។

ចំពោះខ្លឹមសារទាំងមូលនៃសេចក្តីព្រាង យើងឃើញថា មានការរៀបចំបានល្អ មានលំដាប់លំដោយ ល្អ។ គោលបំណងនិងគោលដៅសរសេរដាច់ពីគ្នាបានល្អ ត្រឹមត្រូវ ត្រូវនឹងអ្វីដែលសេចក្តីព្រាងរៀបរាប់។ ការបែងចែកសមត្ថកិច្ច និងកម្រិតនៃការទទួលខុសត្រូវតាមលំដាប់ថ្នាក់បានច្បាស់លាស់។ លក្ខខណ្ឌនិង នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណតាមប្រភេទនីមួយៗក៏រៀបចំបានច្បាស់លាស់ល្អដែរ។ដោយឡែកមាត្រាមួយចំនួន ដែលចែងអំពីបែបបទនិងនីតិវិធីសម្រាប់អនុវត្តបន្តសរសេរថា " កំណត់ដោយប្រកាស ... " តែច្បាប់ចែងថា " ដោយអនុក្រឹត្យ ... " ។ ចំពោះការសរសេរខុសពីច្បាប់បែបនេះ ក្រុមការងាររង់ចាំការពន្យល់បកស្រាយពី ក្រសួង ដើម្បីជួយសម្រួលទៅតាមការជាក់ស្តែង។

ចំពោះពាក្យពេចន៍ ឃ្លាប្រយោគ អង្គប្រជុំក្រុម ក.ស.វ. បានស្នើបន្ថែម និងលុបចោលពាក្យខ្លះ ដើម្បីឲ្យ មានន័យគ្រប់គ្រាន់និងត្រឹមត្រូវ។ អង្គប្រជុំបានចាប់អារម្មណ៍ចំពោះការប្រើពាក្យ "និង" និង "ឬ" និងពាក្យ "នឹង" ប្រើជាមួយកិរិយាស័ព្ទដែលសម្រាប់សម្គាល់អនាគតកាល។ មួយទៀតគឺរបៀបសរសេររៀបរាប់។ បើ ប្រើលេខរៀង ១ ២ ៣ ឬជាអក្សរ ក ខ គ ... គេត្រូវប្រើសញ្ញា "។" នៅចុងបញ្ចប់នៃលេខរៀង ឬអក្សរនីមួយៗ។

សេចក្តីព្រាងអនុក្រឹត្យទាំងបីខាងលើ បានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសពិនិត្យពិភាក្សាកាលពីថ្ងៃ ទី១២ ទី១៣ ទី២០ ទី២១ ទី២៧ ខែឧសភា និងទី៩ ខែមិថុនា ឆ្នាំ២០២០ ក្រោមការដឹកនាំរបស់អនុប្រធាន ក.ស.វ. ឯកឧត្តម **លី គឹមសុខ** និងអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ឯកឧត្តម **ស៊ា ម៉ៅ** ជាសហប្រធាន ដោយមានការចូលរួមពី សមាជិក សមាជិកា ក្រុមការងារនៃ ក.ស.វ. និងក្រុមប្រឹក្សាអ្នកច្បាប់ តំណាងក្រសួង សាមី តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

ជាលទ្ធផល អង្គប្រជុំជំនាញបច្ចេកទេស បានសម្រេចរក្សាចំណងជើងសេចក្តីព្រាងអនុក្រឹត្យស្តីពី លិខិតអនុញ្ញាតសាងសង់ ហើយចំពោះសេចក្តីព្រាងអនុក្រឹត្យពីរទៀត គឺយកដូចមាត្រា៧ និងមាត្រា៤៦ នៃ ច្បាប់ស្តីពីសំណង់។ ចំពោះចំណុចដែលសរសេរខុសពីការចង្អុលរបស់ច្បាប់ អង្គប្រជុំបានឯកភាពប្តូរពាក្យ "នីតិវិធី" (បែបបទនិងនីតិវិធី) ទៅជា "បរិបថ" (បែបបទនិងបរិបថ) វិញ។ ពាក្យពេចន៍ ឃ្លាប្រយោគ និង ខ្លឹមសារមួយចំនួនក៏ត្រូវបានអង្គប្រជុំជំនាញបច្ចេកទេសកែសម្រួលថែមថយ ដើម្បីឲ្យមានសង្គតភាពក្នុងការ តាក់តែង និងស្របតាមលិខិតបទដ្ឋានពាក់ព័ន្ធ។

សេចក្តីព្រាងអនុក្រឹត្យទាំងបី ត្រូវបានដាក់ជូនអង្គប្រជុំអន្តរក្រសួងចង្អៀត នៅថ្ងៃទី២២និងទី២៣ ខែមិថុនា ឆ្នាំ២០២០។

*ដោយ សួង លាងហៃ (ក.ស.វ. - ក្រុម ១)*

## ២- គោលនយោបាយជាតិ

# ពីដំឡូងមី

### ១-សេចក្តីផ្តើម

ក្នុងបរិយាកាសដែលប្រទេសជាតិស្ថិតក្នុងស្ថានភាពសុខសន្តិភាពពេញបរិបូរណ៍កម្ពុជាបានបោះជំហានប្រកបដោយជោគជ័យយ៉ាងធំធេងចេញផុតពីបន្ទាត់ជាប្រទេសក្រីក្រមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ព្រមជាមួយនឹងកំណើនសេដ្ឋកិច្ចកើនឡើងជាប់ៗគ្នានាប៉ុន្មានទសវត្សចុងក្រោយនេះ។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាយ៉ាងមុតមាំក្នុងការពង្រីកនិងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនឱ្យកាន់តែធំនិងសំបូរណ៍បែប ដោយផ្តោតលើវិស័យដែលមានសក្តានុពលធានាបានដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ផ្តល់ឧត្តមប្រយោជន៍ដល់សង្គមជាតិ និងមានឧត្តមភាពប្រកួតប្រជែងពាណិជ្ជកម្មផង។ ជម្រើសមួយសម្រាប់ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនេះគឺការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្មថ្មីដែលមានលក្ខណៈសកម្មនិងថាមវន្ត ហើយមានការចូលរួមយ៉ាងច្រើនកុះករពីប្រជាកសិករ ពលករ ពាណិជ្ជករ និងប្រតិបត្តិករដទៃផ្សេងទៀតដោយបានចាត់ទុកថាការធ្វើទំនើបកម្មវិស័យកសិកម្មជាជម្រើសអាទិភាពដ៏សំខាន់ចាំបាច់បំផុតមួយដែលបានផ្លាស់ប្តូរពីកសិកម្មតាមបែបប្រពៃណីផលិតកម្មតាមបែបគ្រួសារមិនស្របតាមបទដ្ឋានបច្ចេកទេសនិងយថាផលឱ្យទៅជាកសិពាណិជ្ជកម្មដែលភាពសុក្រឹតនៃផលិតកម្មអាចព្យាករណ៍និងគ្រប់គ្រងបាន។ការអភិវឌ្ឍនេះនឹងបង្កើតបាននូវខឿនកសិឧស្សាហកម្មបន្ថែមសម្រាប់ជាតិក្នុងការបង្កើតការងារថ្មីៗនិងអភិវឌ្ឍន៍កសិ-ឧស្សាហកម្មអាចបង្កើនប្រាក់ចំណូលបន្ថែមដល់ប្រជាជននិងផ្សារភ្ជាប់វិស័យផ្សេងៗបង្កើតបាននូវភាពប្រទាក់ក្រឡានៃចរន្តសេដ្ឋកិច្ចនិងបង្កើតឧត្តមភាពក្នុងការនាំចេញផលិតផលពីប្រទេសកម្ពុជាទៅកាន់ទីផ្សារពិភពលោកផង។

ការរីកចម្រើនឆាប់រហ័សគួរជាទីចាប់អារម្មណ៍នៃដំណាំដំឡូងមីនៅក្នុងព្រះរាជាណាចក្រកម្ពុជានាប៉ុន្មានទសវត្សចុងក្រោយនេះបានជំរុញឱ្យដំឡូងមីក្លាយទៅជាដំណាំយុទ្ធសាស្ត្រលំដាប់ទី២បន្ទាប់ពីស្រូវ។លើផ្ទៃដីដាំដុះប្រមាណជា ៦០០ ០០០ហិកតា ដំណាំដំឡូងមីត្រូវការចំណាយថវិកាវិនិយោគប្រមាណជា ៣០០លានដុល្លាក្នុងមួយឆ្នាំ ដែលជាហេតុធ្វើឱ្យដំឡូងមីមានចំណែកប្រមាណជា ៣-៤% នៃផលិតផលសរុបក្នុងស្រុក។ រីឯចំណូលបានមកពីការនាំទៅលក់ច្រកព្រំដែនប្រទេសជិតខាង និងនាំចេញដំឡូងមីស្រស់និងក្រៀមទៅកាន់ទីផ្សារអន្តរជាតិមានប្រមាណជា៧២៨លានដុល្លាក្នុងមួយឆ្នាំ។ក្នុងនោះក៏មានពលករប្រមាណជា១០០០០០នាក់ នៃខេត្តចំនួន ១៣ ក្នុងព្រះរាជាណាចក្រកម្ពុជាដែលកំពុងប្រកបមុខរបរដាំដុះដំឡូងមី និងមានពលករជាច្រើនកំពុងបម្រើក្នុងវិស័យនេះផងដែរ។

**ការកើនឡើងនៃផលិតកម្មដំឡូងមីនៅកម្ពុជា** : ការកើនឡើងនៃនៃតម្រូវការដំឡូងមីក្រៀមចំណិតសម្រាប់ចម្រាញ់ធ្វើជាអេតាណុល និងម្សៅនៅប្រទេសចិន បង្កើតបាននូវប្រព័ន្ធពាណិជ្ជកម្មដ៏សកម្មមួយរវាងអាស៊ីបូព៌ានិងអាស៊ីអគ្នេយ៍។ក្នុងនោះប្រទេសចិនជាប្រទេសបញ្ជាទិញធំជាងគេលើពិភពលោក ហើយប្រទេសវៀតណាមនិងប្រទេសថៃជាប្រទេសផ្គត់ផ្គង់ធំបំផុតសម្រាប់តម្រូវការទីផ្សារចិន។ ប្រទេសទាំងពីរខាងលើនេះបង្កើតទីផ្សារដំឡូងមីនិងប្រព័ន្ធគាំទ្រផលិតកម្មដោយប្រយោលសម្រាប់ប្រទេសកម្ពុជា តាមរយៈការផ្គត់ផ្គង់ធាតុចូលកសិកម្មមានដើមដំឡូងមីការចែករំលែកចំណេះដឹងក្បេត្រសាស្ត្រតាមបណ្តាញក្រៅផ្លូវការដល់កសិករ និងកសាងកន្លែងប្រមូលទិញដំឡូងមីស្រស់ និងចំណិតដំឡូងមីក្រៀម។

**រចនាសម្ព័ន្ធខ្សែច្រវាក់ដំឡូងមី** : ទីផ្សារដំឡូងមីនៅអាស៊ី បានបង្កើតជាខ្សែច្រវាក់តម្លៃតំបន់មួយ ដែលក្នុងនោះកម្ពុជាជាប្រទេសផលិត ប្រមូលផលនិងកែច្នៃបឋម ចំណែកឯប្រទេសជិតខាងទាំងពីរជាអ្នកគ្រប់គ្រងទីផ្សារ និងមានឧត្តមភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម ដើរតួជាអ្នកកែច្នៃ ចរចាថ្លៃនិងនាំចេញទៅកាន់ទីផ្សារ។ នៅក្នុងការអនុវត្តជាក់ស្តែងការនាំចេញដំឡូងមីកម្ពុជាទៅកាន់ប្រទេសចិនដោយផ្ទាល់មានទម្រង់ជាវត្ថុធាតុដើមសម្រេចបានបរិមាណតិចតួច។ ផលិតផលដំឡូងមួយចំណែកធំជាវត្ថុធាតុដើម ត្រូវបានគេដឹកយកទៅកែច្នៃនាំចេញបន្តនៅប្រទេសជិតខាង ។ មានន័យថារហូតមកទល់ពេលនេះកម្ពុជានៅតែបំពេញតួនាទីរបស់ខ្លួនជាអ្នកផ្គត់ផ្គង់ប្រយោលសម្រាប់បំពេញបន្ថែម និងទទួលយកថ្លៃដែលកំណត់ដោយទីផ្សារ។

**និន្នាការទីផ្សារដំឡូងមី**: ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ ពាណិជកម្មដំឡូងមីមានការរអាក់រអួល ដោយសារតម្លៃកសិផលជំនួសមានដូចជាពោតនិងស្រូវសាឡីជាដើមមានការធ្លាក់ចុះធ្វើឱ្យឧស្សាហកម្មកែច្នៃជាច្រើនងាកទៅប្រើប្រាស់វត្ថុធាតុដើមកសិផលជំនួសវិញ ។

អាស្រ័យហេតុនេះហើយទើបបានជា ដើម្បីធានានិរន្តរភាពនៅក្នុងផលិតកម្មដំឡូងមីនៅកម្ពុជាគួរត្រូវបានយកទៅកែច្នៃជាផលិតផលសម្រេចឱ្យបានច្រើនបែបសម្រាប់សេចក្តីត្រូវការរបស់ទីផ្សារប្រកួតប្រជែង។

## ២-ចក្ខុវិស័យ

ដោយមើលឃើញពីការប្រឈមនៃខ្សែច្រវាក់តម្លៃដំឡូងមី និងឱកាសទីផ្សារដែលកំពុងកកើតឡើង រាជរដ្ឋាភិបាលកម្ពុជាសម្រេចធ្វើអន្តរាគមន៍ដោយកំណត់ចក្ខុវិស័យរួមមួយដាក់ចេញនូវគោលនយោបាយជាតិត្រឹមត្រូវ ងាយស្រួលដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីអភិវឌ្ឍវិស័យដំឡូងមីនេះប្រកបដោយនិរន្តរភាពនៅក្នុងផលិតកម្មផ្អែកលើទីផ្សារ ។

## ៣-គោលបំណងនិងគោលដៅ

**គោលបំណង** : ពីឆ្នាំ ២០១៩ រហូតដល់ ២០២៣ រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាទីតាំងឧស្សាហកម្មកែច្នៃដំឡូងមីនិងជាអ្នកផ្គត់ផ្គង់ដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារពិភពលោក។

**គោលដៅ** : ដើម្បីសម្រេចបានគោលបំណងខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការជំរុញការកែច្នៃ និងនាំចេញម្សៅដំឡូងមី ដូចជាម្សៅកែច្នៃបឋមនិងពាក់កណ្តាលសម្រេច នាំចេញម្សៅដំឡូងមីសរីរាង្គដោយផ្អែកលើយន្តការសំខាន់៣ :

-ផ្លាស់ប្តូរពីផលិតកម្មដំឡូងមីតាមបែបប្រពៃណីឬតាមបែបគ្រួសារ ទៅជាដំឡូងមីតាមបែបពាណិជ្ជកម្ម និងអនុវត្តតាមគោលការណ៍បច្ចេកទេស ។

-គាំទ្រអ្នកកែច្នៃផលិតផលដំឡូងមីដែលមានសក្តានុពល និងទាក់ទាញវិនិយោគ ដើម្បីកែច្នៃផលិតផលដំឡូងមីដែលមានភ្ជាប់ទាំងតម្លៃបន្ថែមសម្រាប់ផ្គត់ផ្គង់ទីផ្សារនានា ។

-លើកកម្ពស់ការប្រកួតប្រជែងពាណិជ្ជកម្ម តាមរយៈការជ្រៀតចូលនិងចាប់យកចំណែកនៃទីផ្សារកែលម្អកិច្ចសម្រួលពាណិជ្ជកម្មកាត់បន្ថយការចំណាយដែលមិនចាំបាច់និងផ្សារភ្ជាប់ទៅនឹងអន្តរវិស័យដែលពាក់ព័ន្ធក្នុងការនាំចេញ ។

## ៤-យុទ្ធសាស្ត្រដើម្បីសម្រេចគោលនយោបាយ

ក- ផលិតកម្មផ្អែកលើទីផ្សារ មានន័យថា ទីផ្សារត្រូវបានកំណត់ជាមុន ហើយបន្ទាប់មកខ្សែច្រវាក់តម្លៃផ្គត់ផ្គង់ត្រូវបានរៀបចំតម្រឹមនិងបន្សុីគ្នា។ តួអង្គសំខាន់ៗដែលមានកសិករនិងអ្នកកែច្នៃត្រូវបានលើកទឹកចិត្តឱ្យមានកិច្ចសហការគ្នាតាមរយៈផលិតកម្មតាមកិច្ចសន្យា គម្រោងផលិតកម្មនិងយន្តការដទៃផ្សេងទៀតដែលអាចយកទៅអនុវត្តទទួលបានជោគជ័យ។

ខ-ផលិតកម្មបែបពាណិជ្ជកម្ម ដំណាំដំឡូងមីជាដំណាំយថាភេទមួយដែលប្រជាជនងាយនឹងបោះបង់ការដាំដុះនៅពេលថ្លៃមានការធ្លាក់ចុះ។ ការធ្វើពាណិជ្ជូបនីយកម្មដំឡូងមីត្រូវផ្តើមចេញនិងជំរុញការដាំដុះការស្រាវជ្រាវ និងនវានុវត្តន៍ថ្មី ព្រមជាមួយនឹងការអភិវឌ្ឍផលិតកម្មកសិកម្មតាមបែបសហគមន៍ផលិត។

គ-ការអភិវឌ្ឍឧស្សាហកម្ម ការជួយគាំទ្រនិងលើកទឹកចិត្តអ្នកកែច្នៃដែលមានស្រាប់ និងទាក់ទាញការវិនិយោគធនធានហិរញ្ញវត្ថុនិងបទពិសោធន៍ពាណិជ្ជកម្ម។នេះជាចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរវិស័យនេះនិងជំរុញឱ្យខ្សែច្រវាក់តម្លៃដំឡូងមីឈានឡើងមួយកម្រិតទៀតធ្វើយ៉ាងណាឱ្យសមត្ថភាពកែច្នៃដូចគ្នាឬក៏ប្រហាក់ប្រហែលនឹងបរទេសនិងមានលទ្ធភាពធ្វើការប្រកួតប្រជែងសម្រាប់ទីផ្សារនាំចេញដែលថ្លៃដើមផលិតផលអាចប្រកួតប្រជែងអាចទាញយកប្រយោជន៍ទាំងអស់ពីដើមដំឡូងមីដែលជាកាកសំណល់និងប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនដើម្បីកាត់បន្ថយការបំពុលបរិស្ថាន។ចំណែកឯការវិនិយោគវិស័យដំឡូងនេះក៏ទាមទារឱ្យមានការគាំទ្រនិងលើកទឹកចិត្តផងដែរពីផ្នែកគោលនយោបាយពន្ធ និងហិរញ្ញប្បទាននិរន្តរភាពនានាដែលមានអត្រាការប្រាក់ទាប។

**៥- ផែនការសម្មភាព**

១-ធ្វើឱ្យមានសង្គតិភាពជាមួយគោលនយោបាយជាតិនិងយុទ្ធសាស្រ្តនានាដោយសារការអភិវឌ្ឍវិស័យដំឡូងមីផ្សារភ្ជាប់នឹងវិស័យកសិកម្មនិងពាណិជ្ជកម្មទើបរាជរដ្ឋាភិបាលចាំបាច់ត្រូវអភិវឌ្ឍន៍វិស័យនេះឱ្យស្របទៅនឹងយុទ្ធសាស្រ្តជាតិនិងគោលនយោ បាយពាក់ព័ន្ធនានាដែលមានស្រាប់ឬកំពុងបង្កើត ដើម្បីតម្រឹម បង្គ្រប់និងបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៅក្នុងការអនុវត្ត។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការបន្ទាន់ទាំងនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវផ្តល់អាទិភាពនិងដាក់វិស័យដំឡូងមីជារបៀបវារៈសំខាន់មួយរបស់រាជរដ្ឋាភិបាលនិងវិស័យឯកជន និងវេទិកាគោលនយោបាយពាក់ព័ន្ធនានាផ្សេងទៀត។ ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះឱ្យបានលឿនតាមសេចក្តីត្រូវការ រាជរដ្ឋាភិបាលនឹងសហការជាមួយភាគីពាក់ព័ន្ធ រៀបចំបង្កើតនិងអនុវត្តគម្រោងនានា ដើម្បីបំពេញចន្លោះប្រហោងគម្រោងវិនិយោគរបស់វិស័យឯកជនជាមួយនិងកសិករ។កិច្ចប្រតិបត្តិការនេះត្រូវអនុវត្តក្នុងទម្រង់ជាដៃគូរវាងអ្នកផលិតវិស័យសាធារណៈនិងវិស័យឯកជន ។

២-ផែនការសកម្មភាពរយៈពេល ៥ឆ្នាំ និងទស្សនវិស័យរយៈពេល ១០ឆ្នាំ

ផលិតភាពនៃផលិតផលដំឡូងមីត្រូវបានបង្កើនតាមរយៈការបង្កើនទិន្នផល និងការកាត់បន្ថយថ្លៃដើមនៅក្នុងផលិតកម្ម ដោយមិនបង្កហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម ស្ថិតក្នុងតំណាក់កាលទី១ ដែលមានរយៈពេល២ឆ្នាំ។ដោយឡែកការលើកកម្ពស់ភាពប្រកួតប្រជែងខ្សែច្រវាក់តម្លៃដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ និងកំណើនឧស្សាហកម្មកែច្នៃ ស្ថិតក្នុងតំណាក់កាលទី២ ដែលមានរយៈពេល ៣ឆ្នាំ។

២.១-ការបង្កើនផលិតភាពនៃផលិតផលដំឡូងមីនៅកម្ពុជា

ដើម្បីសម្រេចគោលដៅក្នុងការអភិវឌ្ឍវិស័យដំឡូងមីតាមផែនការខាងលើនេះ បណ្តាស្ថាប័នក្រសួងនានាពាក់ព័ន្ធទៅនឹងកិច្ចគាំទ្រដល់ការអភិវឌ្ឍវិស័យដំឡូងមីចាំបាច់ត្រូវចូលរួមដោះស្រាយបញ្ហាដែលកើតមាននៅក្នុងខ្សែច្រវាក់តម្លៃក្នុងផលិតកម្ម និងកសាងប្រព័ន្ធអភិបាលកិច្ចដោយឡែកមួយ ធ្វើយ៉ាងណាឱ្យវិស័យនេះដំណើរការទៅស៊ីចង្វាក់គ្នាជាមួយនឹងអន្តរវិស័យពាក់ព័ន្ធដទៃផ្សេង និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។

-រៀបចំឱ្យមានតំបន់ខ្សែក្រវាត់ដំឡូងមី តាមរយៈការរៀបចំសិក្សា បង្កើត និងកំណត់ តំបន់ដាំដុះ លើកទឹកចិត្តជំរុញឱ្យកសិករប្រើប្រាស់ដីសមស្របសម្រាប់ដាំដំឡូងមី ដើម្បីធានានូវនិរន្តរភាពបរិស្ថានសេដ្ឋកិច្ចនិងសង្គម ។

-ត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យលើការនាំចូលពូជដើមដំឡូងមីពីក្រៅប្រទេស ក្នុងគោលដៅការពារនិងទប់ស្កាត់ការរីករាលដាលនៃសមាសភាពចង្រៃពីតំបន់មួយទៅតំបន់មួយ ។

-ចរចាជាមួយរដ្ឋាភិបាលប្រទេសនានាក្នុងតំបន់ដើម្បីនាំចូលពូជដំឡូងមីដែលមានទិន្នផលខ្ពស់ធន់នឹងដី ធន់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់ចែកចាយដល់ប្រជាកសិករ។

-លើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជន ឱ្យប្រើប្រាស់ថ្នាលបណ្តុះពូជ និងដើមដំឡូងមីដើម្បីផលិតចែកចាយពូជនិងដើមដែលមានគុណភាពគ្មានជំងឺស្របតាមលក្ខណៈដីរបស់កសិករនិងតម្រូវការរបស់អ្នកកែច្នៃ។

-ត្រួតពិនិត្យតាមដានសមាសភាពចម្រៃ និងកត្តាអវិជ្ជមានដទៃផ្សេងទៀត ដែលប៉ះពាល់ដល់ការផលិតដំឡូងមី។

-ត្រូវផ្តល់សេវាផ្សព្វផ្សាយនិងបញ្ជ្រាបគោលការណ៍ផលិតកម្មដំឡូងមីវៃឆ្លាតដោយអនុវត្តតាមល័ក្ខខ័ណ្ឌបច្ចេកទេស និងការប្រែប្រួលអាកាសធាតុ ។

-កែលម្អសេវាកម្មកសិកម្មឯកជន តាមរយៈរៀបចំឱ្យមានសហគមន៍គ្រឿងយន្ត ឬឧបករណ៍កសិកម្ម ដើម្បីបង្កើនផលិតភាពនិងគុណភាពសេវាកម្មរបស់ពួកគេ។

-រៀបចំកសិករដាំដំឡូងមីជាក្រុមផលិតចង្កោមឬសហគមន៍ហើយធ្វើសមាហរណកម្មអង្គការកសិករទាំងនេះ ទៅក្នុងរចនាសម្ព័ន្ធប្រមូលផ្តុំដែលស្របទៅនឹងតំបន់ ទីតាំងភូមិសាស្ត្រ បរិបទសង្គមសេដ្ឋកិច្ចនិងឆន្ទៈរបស់ពួកគេ។

-ត្រូវជំរុញឱ្យមានកិច្ចសហការរៀបចំទិវាដំឡូងមីជារៀងរាល់ឆ្នាំ( ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ )។

២.២-ការអភិវឌ្ឍន៍វិស័យឯកជនឱ្យកាន់តែរស់រវើក

-ត្រូវជួយបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវវិភាគធ្វើបច្ចុប្បន្នភាពខ្សែចង្វាក់ដំឡូងមីជាទៀងទាត់ នូវតាមរយៈការជួយរោងចក្រសហគ្រាសឧស្សាហកម្មកែច្នៃសម្រេចបាននូវទំហំសេដ្ឋកិច្ច( Economy of Scale ) និងកាត់បន្ថយថ្លៃដើម ដើម្បីឱ្យពួកគេអាចប្រកួតប្រជែងជ្រៀតចូលនិង ក្តាប់ចំណែកទីផ្សារបានប្រកបដោយជោគជ័យ ។

-ត្រូវសិក្សាវិភាគនិងធ្វើបច្ចុប្បន្នភាពខ្សែច្រវាក់តម្លៃដំឡូងមីឱ្យបានទៀងទាត់ តាមរយៈការពិនិត្យពីនិន្នាការទីផ្សារ ការប្រកួតប្រជែងក្នុងតំបន់ និងរចនាសម្ព័ន្ធថ្លៃដើមនៅកម្ពុជា។

-ត្រូវបង្កើតយុទ្ធសាស្ត្រទាក់ទាញវិនិយោគកែច្នៃដំឡូងមីនិងអនុវត្តផែនការសកម្មភាពរបស់ខ្លួនដើម្បីទាក់ទាញវិនិយោគិន សំដៅបង្កើនសមត្ថភាពកែច្នៃដំឡូងមីបំរើគោលដៅនាំចេញ។

-ត្រូវផ្តល់ការលើកទឹកចិត្តដល់ប្រតិបត្តិករដំឡូងមីតាមរយៈការលើកលែងឬកាត់បន្ថយពន្ធលើប្រាក់ចំណេញ ពន្ធលើផលិតផលកែច្នៃពីដំឡូងមី និងអាករលើតម្លៃបន្ថែម ។

- ត្រូវបង្កើតកញ្ចប់ថវិកាពិសេសសម្រួលការលំបាករបស់កសិករ ដើម្បីអន្តរាគមនៅពេលដែលការប្រមូលផលរបស់កសិករលើសលប់ បង្កើតបានជាវិបត្តិដំឡូងមីជន់ ការបិទច្រកព្រំដែនរបស់ប្រទេសជិតខាង ទីផ្សារមានភាពអាក់រអួល កត្តាគ្រោះធម្មជាតិ និងហេតុការណ៍ដ៏ទៃទៀតដែលអាចកើតមានឡើងជាយថាហេតុ។

-ត្រូវគិតគូរអនុវត្តគោលនយោបាយបន្ថយថ្លៃលក់ចរន្តអគ្គីសនីជូនអ្នកប្រើប្រាស់សម្រាប់វិស័យឧស្សាហកម្ម ដែលក្នុងនោះមានទាំងឧស្សហកម្មកែច្នៃដំឡូងមី និងឧស្សហកម្មដទៃផ្សេងទៀត ដោយពុំមានការរើសអើង តាមរយៈការលើកទឹកចិត្តដល់រោងចក្រកែច្នៃដំឡូងមីធ្វើការផលិតអគ្គីសនី ដើម្បីបម្រើសេចក្តីត្រូវការរបស់រោងចក្រផ្ទាល់។អគ្គីសនីសល់ពីការប្រើប្រាស់រោងចក្រអាចធ្វើការចរចាលក់ទៅឱ្យអគ្គីសនីកម្ពុជា។

-ត្រូវជួយជំរុញ និងសម្របសម្រួលដល់កិច្ចដំណើរការរៀបចំវាយតម្លៃពីផលប៉ះពាល់ដល់បរិស្ថាននិងសង្គមសម្រាប់ការកែច្នៃ។

-ត្រូវជួយរោងចក្រដំឡូងមីក្នុងការប្រឹក្សាបច្ចេកទេស ឬបច្ចេកវិទ្យាសមរម្យ។

*ដោយ ទេស អែតដា ( ក.ស.វ. - ក្រុម ២ )*

# ៣- សាលារៀនជំនាន់ថ្មី

ប្រទេសនីមួយៗបានចាត់ទុកការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត។ជានិច្ចកាល ការអប់រំត្រូវការនូវធនធានមនុស្សដែលមានចំណេះដឹងនិងជំនាញប្រកបដោយសមត្ថភាពខ្ពស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក៏ដូចជាកសាងសង្គមជាតិទាំងមូលឱ្យបានរឹងមាំ។ការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយនឹងបណ្ដាប្រទេសក្នុងសហគមន៍អាស៊ាន ទាមទារជាបន្ទាន់នូវកម្លាំងពលកម្មនៅកម្ពុជាប្រកបដោយជំនាញនាសតវត្សទី២១។ តម្រូវការនេះចាំបាច់ទាមទារឱ្យធនធានមនុស្សដែលមានជំនាញខ្ពស់លើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេក-វិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្ដីពីសាលារៀនជំនាន់ថ្មីនៅខែកញ្ញា ឆ្នាំ២០១៦ ក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំទាំងមូល។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី ដែលជាលំនាំបន្តពីកម្មវិធីសាលាកុមារមេត្រី ប៉ុន្តែមានកម្រិតប្រកបដោយស្តង់ដាគុណភាពខ្ពស់។ គោលនយោបាយនេះបានរៀបចំឡើងដើម្បីផ្ដល់ការណែនាំដល់មន្ត្រីគ្រប់គ្រងរដ្ឋបាលអប់រំនិងគ្រូបង្រៀនគ្រប់កម្រិតទាំងអស់ស្ដីពីការអនុវត្តសាលារៀនជំនាន់ថ្មីទូទាំងព្រះរាជាណាចក្រកម្ពុជា។ ការបង្កើតសាលារៀនជំនាន់ថ្មីនេះ គឺជាគោលនយោបាយផ្លូវការមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា អនុលោមតាមក្របខ័ណ្ឌកំណែទម្រង់វិស័យអប់រំដែលបានប្រកាសឱ្យប្រើដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៣ ដែលនៅក្នុងក្របខ័ណ្ឌនេះ សាលារៀនជំនាន់ថ្មីស្ថិតនៅក្នុងចំណុចទី១៤។

ខណៈដែលព្រះរាជាណាចក្រកម្ពុជាបានឈានចូលក្នុងសតវត្សទី២១ យើងឃើញប្រព័ន្ធអប់រំយើងនៅមានបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនេះបានលេចចេញមកពីប្រភពជាច្រើន រួមមានសមាហរណ-កម្មនៃសហគមន៍អាស៊ាន ការកើនឡើងនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជ្រៀតចូលយ៉ាងឆាប់រហ័សនូវប្រព័ន្ធបច្ចេកវិទ្យាក្នុងសង្គមកម្ពុជា ការកើនឡើងនូវផ្នែកនគរូបនីយកម្ម ការពង្រីកសាលារៀនឯកជន និងចំនួនប្រជាជនជាយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលតម្រូវឱ្យមានសេចក្ដីណែនាំទូលំទូលាយអំពីជម្រើស និងគំនិតប្រកួតប្រជែងនៅក្នុងពិភពលោកបច្ចុប្បន្ន។ សាលារៀនជំនាន់ថ្មីនឹងជួយព្រះរាជាណាចក្រកម្ពុជា ដោះ-ស្រាយបញ្ហាប្រឈមទាំងនេះបានតាមរយៈការលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយនិរន្តរភាព។ ធនធានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានៅមានកម្រិត ដូច្នេះការបែងចែកធនធានទាំងនេះឱ្យទៅដល់គ្រប់សាលារៀនទូទាំងប្រទេសបានធ្វើឱ្យគោលដៅលើកកម្ពស់គុណភាពអប់រំនៅជួបបញ្ហាលំបាក។ ជម្រើសគំរូអភិវឌ្ឍន៍ទីពីរដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដោះស្រាយតម្រូវការមូលដ្ឋានរបស់សាលារៀនទាំងអស់នោះ គឺការអនុញ្ញាតឱ្យមានការវិនិយោគកម្រិតខ្ពស់ ដើម្បីទទួលបានស្តង់ដានៃការអប់រំអតិបរមា។ សាលារៀនជំនាន់ថ្មីបង្កើតឡើងដើម្បីបំពេញតម្រូវការខាងលើនេះ។ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាលំនាំបន្តពីកិច្ចខិតខំប្រឹងប្រែងនៃកម្មវិធីសាលាកុមារមេត្រី ដោយយកលំនាំតាមការអនុវត្តនៅក្នុងបណ្ដាប្រទេសមួយចំនួន ដែលសាលារៀនសាធារណៈមួយចំនួនទទួលបានស្វ័យភាពយ៉ាងច្រើនពីរដ្ឋាភិបាលដើម្បីជំរុញនវានុវត្តន៍អប់រំ។ សាលារៀនជំនាន់ថ្មីនឹងនាំមកនូវក្របខ័ណ្ឌរដ្ឋបាលថ្មី ដែលអាចធានាលក្ខខណ្ឌចាំបាច់ជាសារវន្តនិងមានប្រសិទ្ធភាព ក្នុងការធ្វើឱ្យវិនិយោគលើប្រព័ន្ធអប់រំទទួលបានជោគជ័យ។

គិតដល់ឆ្នាំ២០១៨ មានសាលាចំនួន១០ហើយដែលកំពុងដាក់ឱ្យអនុវត្តកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មីនេះ ក្នុងនោះ សាលាបឋមសិក្សាមានចំនួន៤ និងសាលាមធ្យមសិក្សាមានចំនួន៦។ សាលាទាំងនោះរួមមានវិទ្យាល័យ ព្រះស៊ីសុវត្ថិ(រាជធានីភ្នំពេញ) វិទ្យាល័យ ហ៊ុន សែន កំពង់ចាម(ខេត្តកំពង់ចាម) វិទ្យាល័យ ព្រែកលៀប(រាជធានីភ្នំពេញ) វិទ្យាល័យ សម្តេច ជា ស៊ីម ព្រែកអញ្ចាញ(ខេត្តកណ្តាល) វិទ្យាល័យ ហ៊ុន សែន ពាមជីកង(កំពង់ចាម) អនុវិទ្យាល័យ គោកព្រីង(ខេត្តស្វាយរៀង) សាលាបឋមសិក្សា ហ៊ុន សែន កំពង់ចាម(ខេត្តកំពង់ចាម) សាលាបឋមសិក្សាសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ (ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ) សាលាបឋមសិក្សា អង្គរបាន(ខេត្តកំពង់ចាម) និងសាលាបឋមសិក្សា ស្វាយព្រហូត(ខេត្តស្វាយរៀង)។

បំណងសំខាន់នៃការបង្កើតសាលារៀនជំនាន់ថ្មីនេះគឺការព្យាយាមបង្កើតនូវគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័តដើម្បីទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់នឹងស្តង់ដាថ្មី មានគណនេយ្យភាពនិងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅសតវត្សទី២១។ការអភិវឌ្ឍធនធានមនុស្សលើវិស័យអប់រំប្រកបដោយគុណភាពនិងមានគុណធម៌ល្អដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ឱ្យក្លាយជាសង្គមមួយកាន់តែរីកចម្រើនជឿនលឿន ត្រូវផ្អែកលើមូលដ្ឋាននៃចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើ ឱ្យស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក។

* សាលារៀនជំនាន់ថ្មីជាសាលារៀនសាធារណៈស្វយ័តគ្រប់គ្រងដោយវិន័យតឹងរ៉ឹង ក្នុងការបំពេញភារកិច្ច និងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់ ដោយកែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗ ដែលរួមបញ្ចូលទាំងការជ្រើសរើសគ្រូតាមការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ចការបំប៉នសមត្ថភាពគ្រូបង្រៀនលើផ្នែកបច្ចេកទេសបង្រៀនដោយបង្កើននូវវិធីសាស្តថ្មីនិងការសិក្សាឱ្យស្គាល់បញ្ហានិងការរកដំណោះស្រាយ ព្រមទាំងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ភ្ជាប់នឹងឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន(ឧ. អាហារូបករណ៍គ្រូដើម្បីបន្តការសិក្សាពេលអនាគត)។

* នាយក នាយិកាសាលារៀន និងអ្នកគ្រប់គ្រងគ្រប់កម្រិតនឹងទទួលបានការបំប៉នឱ្យក្លាយទៅជាអ្នកដឹកនាំដែលមានបុគ្គលិកលក្ខណៈខ្ពស់និងមានជំនឿលើទស្សនវិស័យរបស់សាលារៀនជំនាន់ថ្មីដោយផ្តោតការយកចិត្តទុកដាក់ខ្លាំង លើការពិនិត្យតាមដានជាប្រចាំនិងជាប្រព័ន្ធវាយតម្លៃការសិក្សារបស់សិស្ស ដោយផ្តល់ព័ត៌មានត្រឡប់ជាប្រព័ន្ធដល់សិស្សគ្រូមាតាបិតានិងសាលារៀន ដែលធ្វើឱ្យប្រព័ន្ធអប់រំមានប្រសិទ្ធភាពនិងសមធម៌សង្គមក្នុងដំណើរការបង្រៀននិងរៀន ដោយមានប្រព័ន្ធបែងចែកធនធានឱ្យសមស្រប។

* ការប្រើប្រាស់បច្ចេកវិទ្យាជាធាតុគន្លឹះក្នុងសាលារៀនជំនាន់ថ្មីដើម្បីជំរុញការច្នៃប្រឌិតថ្មី ដោយមិនគ្រាន់តែរាប់បញ្ចូលការទទួលបាននូវការប្រើប្រាស់ឧបករណ៍រឹងប៉ុណ្ណោះទេ ប៉ុន្តែ សិស្សត្រូវចេះប្រើកម្មវិធីទន់ក្នុងការអប់រំទំនើបទៀតផង ដែលនឹងជួយពង្រឹងដល់ការសិក្សា ការបង្រៀននិងការវាយតម្លៃ (ឧ. កម្មវិធី literatu, 3D classroom ...)។កម្មវិធីសិក្សាSTEMមានមូលដ្ឋានលើគំនិតនៃការអប់រំសិក្សានៅក្នុងមុខវិជ្ជាជាក់-លាក់៤គឺៈ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ សព្វថ្ងៃ ចំណេះដឹង (knowlegde) គឺយើងអាចរកបានតាមមធ្យោបាយផ្សេងៗតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែចំណេះធ្វើជាជំនាញ(skill and soft skill) យើងមិនអាចស្វែងរករៀនចេះក្នុងរយៈពេលខ្លីបានទេ។ កម្មវិធីសិក្សាSTEMផ្តល់សិទ្ធិឱ្យសិស្សក្នុងការជ្រើស-រើសមុខវិជ្ជាSTEMណាមួយ គឺថ្នាក់រូបវិទ្យា ថ្នាក់គីមីវិទ្យា ថ្នាក់គីមីវិទ្យា ថ្នាក់ជីវវិទ្យា ឬថ្នាក់បច្ចេកវិទ្យាព័ត៌មាន។

* ក្រសួងបង្កើតឱ្យមានក្រុមប្រឹក្សាភិបាលថ្នាក់ជាតិដែលមានតួនាទី៖

១- អនុម័តរាល់ការវិនិយោគនិងមូលនិធិសមធម៌សង្គម

២- ត្រួតពិនិត្យការបំពេញតាមគោលការណ៍ស្នូលរបស់សាលារៀនជំនាន់ថ្មី

៣- ចងក្រងនិងកែលម្អគោលនយោបាយសាលារៀនជំនាន់ថ្មី និង

៤-ចេញសេចក្តីសម្រេចទទួលស្គាល់គុណភាពអប់រំ។ក្រសួងក៏នឹងអនុញ្ញាតឱ្យបង្កើតក្រុមប្រឹក្សាភិបាលរាជធានី ខេត្ត ដែលបំពេញបន្ថែមលើមុខងារក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ។ សមាសភាពក្រុមប្រឹក្សាភិបាលគ្រប់ថ្នាក់ ត្រូវឆ្លុះបញ្ចាំងអំពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។សមាជិកភាពនេះ អាចរួមមានតំណាងអង្គការមិនមែនរដ្ឋាភិបាល ពាណិជ្ជករ និងសហគមន៍មូលដ្ឋាន។

* មូលនិធិសមធម៌សង្គមត្រូវបានបង្កើតឡើង សំដៅឆ្លើយតបទៅនឹងកង្វល់ក្នុងសាលារៀនជំនាន់ថ្មី ដើម្បីឱ្យសមាជិកក្រីក្របំផុតក្នុងសហគមន៍ អាចទទួលបាននូវសេវាអប់រំមានគុណភាពខ្ពស់ ដោយមិនធ្វើឱ្យចុះថយនូវលំហូរធនធានដល់សាលារៀនពីសហគមន៍មូលដ្ឋាន។ ប្រភពមូលនិធិសមធម៌សង្គមបានមកពីក្រសួងអប់រំ យុវជន និងកីឡា។ គោលបំណងរបស់មូលនិធិនេះគឺធានាឱ្យសិស្សក្រីក្រដែលគ្មានលទ្ធភាពបង់វិភាគទានស្មគ្រ័ចិត្ត បានចូលរៀននៅសាលារៀនជំនាន់ថ្មី ដោយមិនធ្វើប៉ះពាល់ដល់សាលារៀនក្នុងការផ្តល់សេវាអប់រំដែលមានគុណភាពខ្ពស់។

* សាលារៀនជំនាន់ថ្មីត្រូវបានស្គាល់ថាជា " សាលារៀនមានជម្រើស " មានន័យថា ជាសាលារៀនដែល មានគំរូអប់រំគុណភាពខ្ពស់ ហើយបើកទូលាយសម្រាប់មាតាបិតាសិស្សពីគ្រប់ទិសទី ទោះបីពួកគាត់មិនមានលំនៅឋានចំណុះឱ្យសាលារៀនក៏ដោយ។កូនរបស់ពួកគាត់ត្រូវមានលក្ខណសម្បត្តិសម្រាប់ការជ្រើសរើស ។ក្រោយពីសាលារៀនជំនាន់ថ្មីអាចបង្ហាញភស្តុតាងថាអាចផ្តល់ស្តង់ដាអប់រំខ្ពស់ស្របតាមការទទួលស្គាល់ហើយ មាតាបិតាសិស្សនឹងត្រូវស្នើសុំឱ្យផ្តល់វិភាគភាពស្ម័គ្រចិត្តគាំទ្រសាលារៀន ដើម្បីរក្សាបាននូវស្តង់ដានេះ។ វិភាគទានអាចផ្តើមពីអប្បបរមា ២៦០ ០០០រៀលក្នុង១ឆ្នាំសម្រាប់តំបន់ជនបទ និង ៨០០ ០០០រៀលសម្រាប់តំបន់ទីក្រុង។វិភាគទាននេះធ្វើដោយស្ម័គ្រចិត្តនិងលើកលែងចំពោះគ្រួសារក្រីក្រ។ចំនួនប្រាក់នេះអាចប្រែប្រួលតាមការចរចានិងឯកភាពជាមួយមាតាបិតាសិស្ស ហើយបានការឯកភាពពីក្រុមប្រឹក្សាភិបាល។

សរុបសេចក្តី គំរូកម្មវិធីសាលារៀនជំនាន់ថ្មីបង្កើតបាននូវលក្ខខណ្ឌដើម្បីទទួលបានជោគជ័យ សំដៅធានាការវិនិយោគលើវិស័យអប់រំប្រកបដោយប្រសិទ្ធភាពក្នុងសាលារៀនជាច្រើន។ ការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃទទួលស្គាល់សាលារៀនជំនាន់ថ្មី ដែលធានាស្តង់ដាខ្ពស់នៃអភិបាលកិច្ច មានតម្លាភាព គណនេយ្យភាព និងការចូលរួម បង្កើតបានជាកម្លាំងទាក់ទាញការវិនិយោគថ្មីៗក្នុងវិស័យអប់រំ ដែលការគ្រប់គ្រងអប់រំបែបនេះពុំធ្លាប់មានទេក្នុងវិស័យអប់រំសាធារណៈ។យើងរំពឹងថាការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំយុវជន និងកីឡា ក្នុងការបង្កើតសាលារៀនជំនាន់ថ្មី នឹងទាក់ទាញការវិនិយោគកម្រិតខ្ពស់ជាងមុន ហើយការវិនិយោគទាំងនោះភាគច្រើននឹងទទួលបានពីវិស័យឯកជន។ហេតុនេះ ទស្សនៈសាលារៀនជំនាន់ថ្មីនឹងអាចជួយជំរុញសម្ទុះប្រព័ន្ធអប់រំនៅព្រះរាជាណាចក្រកម្ពុជា ឱ្យមានសមត្ថភាពប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយប្រព័ន្ធអប់រំនៃបណ្តាប្រជាជាតិផ្សេងទៀតក្នុងសហគមន៍អាស៊ាន ដែលកំពុងត្រូវការជាបន្ទាន់នូវកម្លាំងការងារជំនាញក្នុងសតវត្សទី២១នេះ៕

*ដោយ ឆាយ ខុម (ក.ស.វ. - ក្រុម ៣)*

# IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ *



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) លើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលប្រព្រឹត្តទៅនាថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ឆាយលី** ប្រធាន ក.ស.វ. ដែលសមាសភាពចូលរួមមានឯកឧត្តម **នរ៉ាណាឫទ្ធិ អាននូជាយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធាន ក.ស.វ. និងជាប្រធានក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងអនុប្រធាន សមាជិក សមាជិកា និងជំនួយការនៃក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការរៀបចំរបាយការណ៍នេះដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មានទិន្នន័យពីក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីថ្នាក់ដឹកនាំ ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកានៃក.ស.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាននៃក.ស.វ. តាមប្រព័ន្ធគេហទំព័រ។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី១ ឆ្នាំ២០២០ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,២% ធៀបនឹងត្រីមាសមុន និងកើនឡើង៣,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន | +៤,៥% | ត្រីស្រស់ | +៧,៧% |
| ម្ហូបអាហារ | +៣,៨% | អង្ករ | +៤,១% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +៣,៧% | ផ្លែឈើ | +៣,៨% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៤% | បន្លែ | +៣,៦% |
| ការសិក្សា | +២,៩% | ឧស្ម័ន | +៣,៤% |
| ការដឹកជញ្ជូន | +២,៦% | សាច់មាន់ស្រស់ | +២,៩% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +២,៤% | សាច់គោស្រស់ | +២,៧% |
| សំលៀកបំពាក់ និងស្បែកជើង | +២,១% | សាច់ជ្រូក | +២,១% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +១,១% | | |
| ការកម្សាន្ត និងវប្បធម៌ | +១,០% | | |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +០,៤% | | |
| សុខាភិបាល | +០,២% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។
ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២. អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី១ ២០២០* | *ត្រីមាសទី៤ ២០១៩* | *ត្រីមាសទី១ ២០១៩* | *បរិយាយ* | *ត្រីមាសទី១ ២០២០* | *ត្រីមាសទី៤ ២០១៩* | *ត្រីមាសទី១ ២០១៩* |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤ ០៧០៛/$ | ៤ ០៧៥៛/$ | ៤ ០១៥៛/$ | **បាត/ដុល្លារ** | ៣២,៧បាត/$ | ៣០,០បាត/$ | ៣១,៨បាត/$ |
| **៛/បាត** | ១២៥៛/បាត | ១៣៦៛/បាត | ១២៦៛/បាត | **ដុង/ដុល្លារ** | ២៣៦៣៣ដុង/$ | ២៣ ១៧១ដុង/$ | ២៣ ២០០ដុង/$ |
| **៛/ដុង** | ០,១៧២៛/ដុង | ០,១៧៦៛/ដុង | ០,១៧៣៛/ដុង | **យ៉ន់/ដុល្លារ** | ៧,១យ៉ន់/$ | ៧,០យ៉ន់/$ | ៦,៧យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី១ ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨ និង ២០១៩




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៥ ៥៤៤,០ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៣៨៦,០ លានដុល្លារ (*មធ្យមប្រចាំខែ ៩១,១%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ៥ ៥២៣,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ៣៨១,០ លានដុល្លារ (*មធ្យមប្រចាំខែ ៩២,៥% នៃផែនការ*) និងចំណូលមូលធនចំនួន ២០,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៥,០ លានដុល្លារ (*មធ្យមប្រចាំខែ ១៨,២% នៃផែនការ*) (តាមតួលេខ ធនាគារជាតិ)។

➤បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិថយចុះ ២៨,១% ប៉ុន្តែកើនឡើង ៨,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ ២០១៩។

➤នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៥ ៣២៩,៨ប៊ីលានរៀល ថយចុះ ១៨,២% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង៤,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន (តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខធនាគារជាតិ ចំណូលសារពើពន្ធមានចំនួន ៤ ៦៩៧,១ ប៊ីលានរៀល ថយចុះ ២៤,៦% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង៣,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៨២៦,៨ ប៊ីលានរៀលថយចុះ ២៤,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែ កើនឡើង ៥២,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :-៨,៧% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៧,០%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៥០,៤% | កើនគំហុក |
| | | ➢ នេសាទ: -១៣,២% | (-៧៣,២%) |
| ➢ ចំណូលពន្ធដារ: -២៨,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+១,៣%) | ➢សម្បទានរ៉ែ: -២០,៧% | (+៣៥,៧%) |
| | | ➢អាកាសចរណ៍ស៊ីវិល: +៤៥,១% | (+៨១៤,៧%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៣១,០% | (-១៣,០%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៤ ៦៦០,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ១៦៥,១ លានដុល្លារ( *មធ្យមប្រចាំខែ ៦០% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៣ ៧៧៨,១ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨៤% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៨៨២,២ ប៊ីលានរៀល (តាមតួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៨-២០១៩




➢ចំណាយថវិកាជាតិថយចុះ ២៩,៣% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង ៥៧,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះៈចំណាយចរន្តថយចុះ ៨,០% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង ៤០,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១នេះ មានអតិរេកចំនួន ៨៨៣,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ២២០,៩ លានដុល្លារ (តួលេខ រតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី១ ឆ្នាំ២០២០មានលក្ខណៈដូចខាងក្រោម:

➤រូបិយវត្ថុ$M_2$ មានចំនួន ១១៩ ២២២,៨ ប៊ីលានរៀលមានការកើនឡើង០,៧%ធៀបនឹងខែមុននិងកើនឡើង ១៣,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ៨,២% និងប្រាក់បញ្ញើផ្សេងទៀត០,៨%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុត្រីមាសទី១ ឆ្នាំ២០២០




➤ក្នុងខែនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៤% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៦% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៥,៦% | ១៥,៧% | ១៦,៤% | | | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៤,៤% | ៨៤,៣% | ៨៣,៦% | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី១ ឆ្នាំ២០២០
(ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)




តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ត្រីមាសទី១ ២០២០ | ត្រីមាសទី៤ ២០១៩ | ត្រីមាសទី១ ២០១៩ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១១២ ៦៦៨,៧ | ១០៧ ៥៩៤<br>១០ ៩៦២,២ | ៨៧ ៥៦៤,២<br>៤ ៥៧៦,៧ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ២៩ ៣៥៧,៥ | ២៤ ០២០,៣ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៥% | ៤,១% | ៥,៣% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៣% | ៣,៤% | ៣,៤% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,២% | ៨,៦% | ១១,០% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,០% | ៨,០% | ៨,៤% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៧,៦% | ១៧,៨% | ១៧,៩% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,១% | ១៦,១% | ១៦,៧% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី១ ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ១៦៦,០ ពាន់តោនថយចុះ៤៦,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង ៣,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២ ៩៨០,៧ GWh មានការកើនឡើង០,៥% ធៀបនឹងត្រីមាសមុននិង កើនឡើង១២,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ២៥៩,៩ GWh មានការថយចុះ៧៥,២% ធៀបនឹងត្រីមាសមុន និងថយចុះ៤៣,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ១ ១៨៩,៥ GWh មានការកើនឡើង១៩,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៨,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ១ ២៤៦,២ GWh មានការកើនឡើង៧៦,១% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង៥៨,០%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ២៨៥,0 GWh មានការកើនឡើង ៣៤,៣% ធៀបនឹងត្រីមាសមុនប៉ុន្តែ ថយចុះ៣,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មស៊ីម៉ង់ត៍មានចំនួន ២ ០៨០,១ ពាន់តោនមានការកើនឡើង១១,៨% ធៀបនឹងត្រីមាសមុន និងកើនឡើង១,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—ត្រីមាសទី១ ២០២០* | *ចំនួន—ត្រីមាសទី៤ ២០១៩* | *ចំនួន—ត្រីមាសទី១ ២០១៩* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៧៧ | ៥៦ | ៥៩ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨០១ | ១ ៧៣០ | ១ ៥៧១ |
| ▪ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | ២៣ | ១៥ | ១៥ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣០ | ១១ | ១៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៥ ៧៣៧,៣ ពាន់ម² មានការថយចុះ៤៤,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៥០,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ២ ៥៧៤,២ លានដុល្លារមានការថយចុះ៤៧,៩% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង ៥១,២% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន :

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម² — ត្រីមាសទី១ ២០២០* | *ពាន់ម² —ត្រីមាសទី៤ ២០១៩* | *ពាន់ម² —ត្រីមាសទី១ ២០១៩* |
|---|---|---|---|
| ▪ លំនៅឋាន | ៣ ៣៧១,០ | ៤ ៧៩៦,១ | ២ ៥៥៩,៨ |
| ▪ ឧស្សាហកម្ម | ៤៤៩,៨ | ១ ៥០៤,៩ | ៣០៩,៨ |
| ▪ពាណិជ្ជកម្ម | ១ ៣៦២,៨ | ៣ ៣៩៩,០ | ៧៨៩,០ |
| ▪ ទេសចរណ៍ | ២១១,២ | ៥១៨,៣ | ១១០,៧ |
| ▪ផ្សេងៗ | ០,៩ | ៣,៨ | ១,៩ |
| អនុញ្ញាតសរុប | ៥ ៧៣៧,៣ | ១០ ២៥៦,៧ | ៣ ៨២០,៩ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺ លំនៅដ្ឋាន ៥៨,៨% និងពាណិជ្ជកម្ម២៣,៨% នៃផ្ទៃក្រឡាសរុប។

### ➢សេវាកម្ម

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –ត្រីមាស ទី១ ២០២០ | ចំនួន–ត្រីមាស ទី៤ ២០១៩ | ចំនួន–ត្រីមាស ទី១ ២០១៩ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ៩០០ | ១ ៨៨៥ | ៤ ២០៨ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៨០ | ៦១ | ៣៣ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ២ ១១៣ | ២ ៧១០ | ២ ៥៩១ |

### ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាស ទី១ ២០២០ | នាក់–ត្រីមាស ទី៤ ២០១៩ | នាក់–ត្រីមាស ទី១ ២០១៩ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបរ និងការងារ) | ៣ ៥២១ | ៤ ៤៣៨ | ៤ ៤៧៦ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើសឯកជន | ៨៤ ៧៨៤ | ៦៣ ៥៦៨ | ៥៣ ៦៧៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៦៥ ៤៧៣ | ៤៦ ១៩៤ | ៣៨ ៥០២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៩ ៣១១ | ១៧ ៣៧៤ | ១៥ ១៧៤ |

### ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី១ ២០២០ | ត្រីមាសទី៤ ២០១៩ | ត្រីមាសទី១ ២០១៩ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១ ០៣២,០ | ២ ៨១៣,០ | ២ ៣២៤,៥ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២០,២ | ៩០,៧ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២៨៦,៧ (៨៧,០) | ៥៥៩,៥ (៣៦១,០) | ៦៩៨,៩ (៣៦៣,៤) |
| វិស័យទេសចរណ៍ | ១៣៣,០ | ១ ៧៣១,២ | ១ ៦១៨,៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៥៩២,១ | ៤៣១,៦ | ៦,៨ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៦២ | ៧១ | ៩៤ |
| បង្កើតការងារ (ពាន់នាក់) | ៤៣,១ | ៦៦,៤ | ១១២,៧ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ២ ៥៥៥,៧ ពាន់តោន មានការថយចុះ១,៧% ធៀបនឹងត្រីមាសមុនប៉ុន្តែមានការកើនឡើង៤,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:-២,៤% (+២,២%) | ▪ កំពង់ផែកំពង់សោម:-១,៣% (+៥,៧%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន – ត្រីមាស ទី១ ២០២០ | ចំនួន–ត្រីមាស ទី៤ ២០១៩ | ចំនួន–ត្រីមាស ទី១ ២០១៩ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ១៣៩,១ | ១៤១,៩ | ១៦២,២ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៣០,១ | ២៣,២ | ៣០,២ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៩១៦ | ៩៦៥ | ១០៧៥ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាស មុន | %Δធៀបនឹងត្រីមាស ដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៦៥,០ | -១០,៦% | ៧,៦% |
| ក្នុងនោះទទួល | ៧,៨ | -២,២% | +៨,៤% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ២៤២,៤ | -១៦,៩% | -២១,១% |
| ក្នុងនោះទទួល | ១៣២,៩ | -១៩,៤% | -១៧,០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៣ ៨៣៤,១ | -១២,៨% | -២១,៨% |
| ក្នុងនោះហៅចូល | ១ ៥១៧,០ | -១០,៦% | +០,៣% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១១ ៤៣៦,៥ | -១៣,៤% | -៤៥,០% |
| ក្នុងនោះហៅចូល | ១១ ២៥៤,០ | -១៣,៩% | -៤៥,៣% |

## ➢ ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹង ត្រីមាសមុន | %Δធៀបនឹងត្រី មាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤៣,៧ | -១២,៥% | -៣៥,៣% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ៣៨៣,៧ | -២៩,៤% | -៥១,៣% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ២៨,៤ | +៦,១% | -៥,២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៤០,៣ | -២៩,៦% | -៣៧,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១ ៦២៥,១ | -៣៣,៧% | -៤៣,៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៣០៨,៤ | -៣៩,២% | -៣២,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ១៥៥,២ | -៣៥,៧% | -៣៨,៥% |
| ✓ តាមផ្លូវអាកាស | ៦៦៣,៦ | -៣៤,៣% | -៤៨,៩% |
| ✓ តាមផ្លូវគោក និងទឹក | ៤៩១,៦ | -៣៧,៥% | -១៥,១% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី១ ឆ្នាំ២០២០ មានចំនួន ១៩ ៣១៧,៤ ប៊ីលានរៀល (ស្មើនឹង ៤ ៨២៩,៣ លានដុល្លារ ស.រ.អា.) ថយចុះ៦,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង៩,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៨,២% | +៨,៧% | រថយន្តសរុប (ប៊ី.ល.រ) | -១៤,៦% | +១១,៩% |
| ប្រេងម៉ាស៊ូត | -១,០% | +៩,៣% | រថយន្តសរុប (គ្រឿង) | -២០,៩% | +៨,២% |
| ឧស្ម័ន | -១៤,៤% | +២,៧% | ត្រាក់ទ័រនិងគោយន្ត | -៥,០% | -១៥,៦% |
| អគ្គិសនីនាំចូលដោយ | +៧៦,១% | +៥៨,០% | ម៉ូតូ (គ្រឿង) | -៦,៤% | -៤,៤% |
| ដែកសំណង់ | -៤០,៣% | -៤៤,៤% | អង្ករ | +៣៩,០% | -៣៤,៤% |
| ស៊ីម៉ង់ត៍ | -៤២,២% | +២៤,៥% | ផ្លែឈើនិងបន្លែ | +១២១,១% | +១៤៧,៥% |
| គ្រឿងអេ | -៧៤,៦% | -៣២,៩% | ថ្នាំកសិកម្ម | -៤១,៣% | +៣២,៥% |
| | | | នាំចូលក្នុងក្របខណ្ឌ | -៤,៧% | +៨,៦% |

➡ **ការនាំចេញ** ត្រីមាសទី១ ឆ្នាំ២០២០ មានចំនួន **១៤ ៣៦០,៣** ប៊ីលានរៀល ស្មើនឹង **៣ ៥៩០,១** លានដុល្លារ ស.រ.អា. (**៧៤,៣**% នៃការនាំចូល)ថយចុះ៤,៣% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង១១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +១៨៤,៦% | -៣៤,៨% | ផលិតផលនេសាទ | -៩,៧% | -៣០,១% |
| វាយនភណ្ឌនិងស្បែកជើង | -០,៥% | +៦,៦% | កៅស៊ូ | -៥៩,៩% | -៣៤,៣% |
| អង្ករ | +១៥,០% | +៣៣,២% | | | |

# ១- ផលប៉ះពាល់កូវីដ១៩ លើសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា

## សេចក្តីផ្តើម

កូវីដ១៩ បានបណ្តាលឱ្យមានការឆ្លងជាង ៨លាននាក់ ស្លាប់មានជាង ៤៣ម៉ឺននាក់ និងជាសះស្បើយឡើងវិញជាង ៤លាននាក់ គិតត្រឹមព្រឹកថ្ងៃអង្គារ ទី១៦ ខែមិថុនា ឆ្នាំ២០២០នៅទូទាំងពិភពលោក ឯតួលេខកម្ពុជាមានករណីជំងឺកូវីដ១៩ចំនួន១២៨ករណីជាសះស្បើយសរុបមានចំនួន១២៥នាក់ស្លាប់គ្មាននិងអ្នកជំងឺនៅសល់សំរាកព្យាបាលនៅមន្ទីរពេទ្យចំនួន ៣នាក់។ប្រទេសជិតខាងយើងនិងពិភពលោកកំពុងបន្តរាតត្បាតជំងឺកូវីដ១៩ ដ៏ខ្លាំងក្លានៅឡើយ។ ព្រឹត្តិការណ៍នេះ បានបង្កការភ័យខ្លាចចំពោះសកលលោកទាំងមូល និងកម្ពុជា នូវវិបត្តិពីរ (១) ការឆ្លងរាតត្បាតកូវីដ១៩ក្នុងផ្ទៃប្រទេស (២) ការធ្លាក់ចុះនៃសេដ្ឋកិច្ច ឬវិបត្តិសេដ្ឋកិច្ច។ ប្រទេសនីមួយៗបានឆ្លើយតបដូចគ្នាទៅនឹងកូវីដ១៩ បិទទ្វាប្រទេស កំហិតការធ្វើដំណើរ បង្ខាំងខ្លួនក្នុងផ្ទះ រៀងខ្លួនចត្តាឡីស័កអ្នកជំងឺបិទសកម្មភាពសេដ្ឋកិច្ចសាលារៀន។ល។សកម្មភាពទាំងនេះបណ្តាលឱ្យមានការធ្លាក់ចុះនៃនិយោជន៍ក្នុងវិស័យជាច្រើន មនុស្សមួយចំនួនបាត់បង់ការងារ តម្រូវការទំនិញនិងសេវាថយចុះ រីឯតម្រូវការខាងវេជ្ជសាស្រ្តនិងស្បៀងអាហារមានការកើនឡើង។ ដើម្បីស្វែងយល់ពីឥទ្ធិពលអវិជ្ជមានលើសេដ្ឋ-កិច្ច ខ្លឹមសារនៃអត្ថបទនេះ សង្កត់ធ្ងន់លើការពិនិត្យមើលទិដ្ឋភាពរួមដែលកូវីដ១៩ បង្កឥទ្ធិពល ក្នុងនោះ (១) វិស័យរងឥទ្ធិពលផ្ទាល់ (២) វិស័យរងឥទ្ធិពលប្រយោល (៣) ឥទ្ធិពលលើសង្គម។

យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (ADB)[1] ដែលចេញផ្សាយក្នុងខែមេសា សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០នេះ រំពឹងថានឹងមានកំណើនត្រឹមតែ ២,៣%។ ការធ្លាក់ចុះនេះមិនចំលែកទេ គឺជានិន្នាការរួមនៃពិភពលោក ដែលស្ថិតក្រោមឥទ្ធិពលនៃវីរុសកូវីដ១៩ ក្នុងនោះ ការប៉ះពាល់ធ្ងន់ធ្ងរនឹងកើតឡើងចំពោះ វិស័យសេវាកម្ម ជាពិសេសទេសចរណ៍ កម្មន្តសាល និងសំណង់ដោយសារការបង្អាក់ខ្សែរច្រវ៉ាក់ផ្គត់ផ្គង់ និងការថមថយតម្រូវការ។

ដោយឡែកក្នុងដើមខែមិថុនានេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញការវាយតម្លៃរបស់ខ្លួន ដោយទំលាក់អត្រាកំណើនទៅជាអវិជ្ជមាន -១,៩% ប៉ុន្តែក្នុងឆ្នាំបន្ទាប់ ២០២១ កំណើនសេដ្ឋកិច្ចនឹងងើបឡើងវិញ ក្នុងរង្វង់ ៣,៥%។

| | ២០១៨ | ២០១៩វ | ២០២០ព្យ | ២០២១ព្យ |
|---|---|---|---|---|
| កំណើន ផ.ស.ស | ៧,៥% | ៧,១% | ២,៣% | ៥,៧% |
| កំណើនវិស័យកសិកម្ម | ១,២% | ១,៨% | ០,៥% | – |
| កំណើនវិស័យឧស្សាហកម្ម | ១១,៦% | ១០% | ៦,៥% | – |
| កំណើនវិស័យសេវាកម្ម | ៦,៧% | ៦,៦% | ៤,៩% | – |
| សម្គាល់៖ វ – វាយតម្លៃ, ព្យ – ព្យាករណ៍ | | | | |
| ប្រភព៖ NBC & ADB (ការព្យាករខែមេសា) | | | | |

[1]Asian Development Outlook (ADO) 2020

## ១. វិស័យរងឥទ្ធិពលផ្ទាល់

### ១.១. កម្មន្តសាល

កម្មន្តសាលត្រូវបានព្យាករថានឹងមានកំណើនតែ៦,៥%ក្នុងឆ្នាំ២០២០(ក្នុងឆ្នាំ២០១៩វិស័យនេះមានកំណើនក្នុងរង្វង់ ១០%)។

### ១.២. ទេសចរណ៍ និងការធ្វើដំណើរ

ស្ថិតិរបស់ក្រសួងទេសចរណ៍បានអោយដឹងថានៅក្នុងឆ្នាំ២០១៩កន្លង ភ្ញៀវទេសចរចូលមកទស្សនាប្រទេសកម្ពុជាមានប្រមាណ ៦,៦លាននាក់ ក្នុងនោះ មកតាមផ្លូវអាកាស ៤,៤លាននាក់ និងទេសចរណ៍ចិន ២,៣លាននាក់ ឈរក្នុងលំដាប់ថ្នាក់លេខ១ ស្មើ ៣៥% នៃភ្ញៀវទេសចរសរុប រីឯទឹកប្រាក់ចូលពីវិស័យទេសចរណ៍មានប្រមាណ៥ពាន់លានដុល្លារ ខណៈភ្ញៀវក្នុងស្រុកផ្តល់ចំណូលប្រមាណ ០,៥ពាន់លានដុល្លា។

វិស័យបដិសណ្ឋារកិច្ចកម្ពុជាបាននិងកំពុងរងការប៉ះពាល់អវិជ្ជមានជាមួយនឹងវិបត្តិអាកាសចរណ៍ស៊ីវិលដែលប្រឈមការលុបចោលការធ្វើដំណើរយ៉ាងច្រើនឥតគណនា និងការបិទព្រំដែននៅទូទាំងពិភពលោក។ ក្នុងរយៈពេល២ខែដើមឆ្នាំ២០២០នេះ អ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា បានថយចុះប្រមាណ៥០% ធៀបនឹងពេលដូចគ្នានៃឆ្នាំ២០១៩។ ការណ៍នេះ ធ្វើឱ្យរមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទីកម្សាន្តដ៏ទៃទៀត ត្រូវបិទទ្វារមួយរយៈ រំសាយបុគ្គលិកមួយចំនួន។ សម្ពាធហិរញ្ញវត្ថុកើតមានឡើងទាំងចំពោះ សហគ្រាស ទាំងកម្មករនិយោជិត។

ក្រុមប្រឹក្សាគមនាគមនិងទេសចរណ៍ពិភពលោក (The World Travel and Tourism Council) បានព្រមានថា ការងារចំនួន ៥០លានកន្លែងអាចនឹងបាត់បង់នៅក្នុងវិស័យគមនាគមនិងទេសចរណ៍នៃសកលលោក[2] ។ នៅអឺរ៉ុប គ្រឹះស្ថានទេសចរណ៍ទទួលបាន ការឧបត្ថម្ភបណ្តោះអាសន្នពីរដ្ឋាភិបាល ច្រកស្វែងរកកម្ចីរហ័សជាមួយការប្រាក់ទាប ដើម្បីជៀសពីកង្វះសាច់ប្រាក់។

### ១.៣. អចលនទ្រព្យ និងលំនៅឋាន

មានការគិតថា អាចមានវិបត្តិហិរញ្ញវត្ថុមួយទៀត ស្រដៀងក្នុងឆ្នាំ២០០៨ ដែលនឹងជះឥទ្ធិពលដល់ទីផ្សារអចលនទ្រព្យ។វិស័យនេះកំពុងជួបភាពមិនប្រាកដប្រជា ការបង្ខាំងខ្លួនក្នុងផ្ទះ និងការប្រុងប្រយ័ត្នខ្លួនក្នុងទំនាក់ទំនងសង្គម ការកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចនិងចំណូល ធ្វើឱ្យមានការកែប្រែលំហូរវិនិយោគ ការផ្លាស់ប្តូរទស្សនៈនិងតម្រូវការលើផ្ទះសម្បែង។ប៉ុន្តែដោយយោងស្ថានភាពដុះដាលនៃអចលនទ្រព្យកម្ពុជា វិស័យនេះមិនអាចធ្លាក់ដល់បាតទេ ហើយត្រៀមខ្លួនជាស្រេចក្នុងការស្ទុះឡើងជាថ្មី។ ប៉ុន្តែក្តីបារម្ភ ទោះបីថាមិនព្រួយដូចវិស័យផ្សេងក៏នៅតែមានចំពោះកម្មកររាប់ពាន់នាក់ក្នុងវិស័យនេះដែលអាចបាត់ការងារមួយរយៈ ឬជាអចិន្ត្រៃយ៍។ លើសពីនេះ គួរកត់សម្គាល់បន្ទុករបស់កម្មករក្នុងការបង់ឈ្នួលផ្ទះ ការប្រាក់ និងការចំណាយផ្សេងៗក្នុងគ្រួសារ។ ក្នុងបញ្ហានេះ រាជរដ្ឋាភិបាលមានវិធានការណ៍មួយចំនួន រាប់ចាប់ពីការឧបត្ថម្ភគាំទ្រសុខុមាលភាពជាសាច់ប្រាក់និងការចរចារជាមួយនិយោជកនិងស្ថាប័នហិរញ្ញវត្ថុផ្តល់ជូននូវសម្បទានដែលអាចធ្វើបានដល់អ្នកទីទាល់ខ្លាំង។ ទោះជាយ៉ាងណាផលប៉ះពាល់នៃកូវីដ១៩រហូតមកដល់ពេលនេះអាចនិយាយថា មិនទាន់មានឥទ្ធិពលអវិជ្ជមានគួរឱ្យកត់សម្គាល់លើទីផ្សារលំនៅដ្ឋានទេ។

[2] Available from: https://www.weforum.org/agenda/2020/03/world-travel-coronavirus-covid19-jobs-pandemic-tourism-aviation/

### ១.៤. ការដឹកជញ្ជូន

វិស័យដឹកជញ្ជូនមានចំណងទាក់ទងខ្លាំងនឹងថ្លៃប្រេងឥន្ធនៈ។កិច្ចប្រជុំមួយរបស់អង្គការនៃប្រទេសនាំប្រេងចេញ ( OPEC ) នៅទីក្រុង Vienna នាថ្ងៃទី៦ ខែមីនា និងការបដិសេធរបស់រុស្ស៊ីក្នុងការកាត់បន្ថយផលិតកម្មប្រេងបានធ្វើឱ្យអារ៉ាប់ប៊ីសាអូឌីតសងសឹកដោយការបន្ទាបថ្លៃនិងការគំរាមបង្កើនការបូមបន្ថែមទៀត។ប្រទេសនេះត្រូវបានចាត់ទុកថាជាមេដឹកនាំ OPEC បានបង្កើនការផ្គត់ផ្គង់ប្រេងក្នុងខែមីនាចំនួន២៥% លើសខែកុម្ភៈជាបរិមាណផលិតដែលមិនធ្លាប់មានពីមុន។ ម៉្យាងទៀតពីជ្រុងខាងតម្រូវការ មានការធ្លាក់ចុះក្នុងរយៈពេលខ្លីដោយសារការចុះខ្សោយនៃសកម្មភាពផលិត និងការប្រើប្រាស់ក្នុងអំឡុងពេលចលចលនៃកូវីដ១៩។

ការណ៍នេះបណ្តាលឱ្យថ្លៃប្រេងធ្លាក់ចុះដល់ចំណុចទាបបំផុតក្នុងអំឡុង៣០ឆ្នាំពោលគឺនៅថ្ងៃ២៣ខែមីនា ប្រេងឆៅបានធ្លាក់ថ្លៃ ២៤% ដល់ ៣៤ដុល្លារ/បារ៉ែល និងបន្ទាប់ឈរទ្រឹងនៅត្រឹម ២៥,៧០ដុល្លារ/បារ៉ែល[3]។ ទោះថាការសាយភាយកូវីដ១៩ មានការថមថយក៏ដោយ ក៏នៅតែស្រពេចស្រពិលជាមួយនឹងថ្លៃប្រេងដែលអាស្រ័យខ្លាំងលើភាពរកាំរកូសនិងការសម្រេចចិត្តផលិតរបស់អារ៉ាប់ប៊ីសាអូឌីតនិងរុស្ស៊ី ។

## ២. វិស័យរងឥទ្ធិពលប្រយោល

### ២.១. កសិកម្ម

ដោយសារការចុះខ្សោយនៃសកម្មភាពនាំចេញនាំចូល ផលិតផលកសិកម្មមួយចំនួនរងការប៉ះពាល់ ប៉ុន្តែជារួមវិស័យនេះ ក្នុងកម្រិតណាមួយ រក្សាភាពធន់ជាមួយកូវីដ១៩ ព្រោះតម្រូវការលើម្ហូបអាហារនៅតែខ្ពស់។

ម្ហូបអាហារ កាលណាមានភាពតានតឹងនិងការភិតភ័យ ប្រជាជនតែងបង្កើនការទិញដើម្បីស្តុក ដូច្នេះការខ្វះខាតស្បៀង ដូចជាអង្ករ សាច់ និងបន្លែ ទោះថាអាចមិនកើតឡើង ក៏ការឡើងថ្លៃអាចកើតមានឡើង។

### ២.២. ហិរញ្ញវត្ថុ និងរូបិយវត្ថុ

ស្ថាប័ននិងទីផ្សារហិរញ្ញវត្ថុ ក៏រងសម្ពាធពីកូវីដ១៩ តាមរូបភាពដែលបង្អាក់ខ្សែច្រវាក់តម្រូវការនិងការផ្គត់ផ្គង់។រាជរដ្ឋាភិបាលរំពឹងថាមានចំណាយខ្ពស់លើសង្គមកិច្ចនិងសុខុមាលភាពអ្នកងាយរងគ្រោះ ចំណាយវិនិយោគមានកម្រិត ឯខ្ទង់ចំណូលមានការថមថយ។ វិស័យឯកជនក៏មានការចុះខ្សោយសកម្មភាពវិនិយោគ ប៉ុន្តែរំពឹងថានឹងស្ទុះឡើងលឿនវិញ ក្រោយការរលត់នៃចំហាយកូវីដ១៩។ ជាលទ្ធផល ក្នុងឆ្នាំ២០២០នេះតម្រូវការលើរូបិយវត្ថុនឹងថយចុះមួយកម្រិតដូច្នេះសូចនាកររូបិយវត្ថុកម្ពុជាក្នុងឆ្នាំ២០២០-២១អាចមានកំណើនទាប។

លើសកលលោកធនាគារកណ្តាលនៃបណ្តាប្រទេសបានអន្តរាគមដើម្បីផ្តល់សាច់ប្រាក់និងជួយសម្រាលទម្ងន់វិបត្តិ ដោយផ្តោតលើ "ការបន្ទាបការប្រាក់" ជាមួយនឹងកញ្ចប់នៃគោលនយោបាយសារពើពន្ធ តាមរយៈការបង្កើនបំណុលសាធារណៈ មានន័យថា ធនាគារកណ្តាលត្រូវទិញមូលបត្ររតនាគារពីឯកជនក្នុងទំហំធំ។

### ២.៣. សិក្សាធិការ

កូវីដ១៩ក៏ជះឥទ្ធិពលដល់ប្រព័ន្ធអប់រំគ្រប់កំរិតពីថ្នាក់មត្តេយ្យដល់ឧត្តមសិក្សា។កម្ពុជាបានប្រកាសបិទទ្វារគ្រឹះស្ថានសិក្សាបណ្តោះអាសន្ននៅទូទាំងប្រទេស ដែលក៏ជាកត្តាបង្កការប្រែប្រួលដល់សេដ្ឋកិច្ចសង្គមកិច្ច។

---

[3] Oil Prices, Stocks Plunge After Saudi Arabia Stuns World With Massive Discounts. Available from: https://www.npr.org/2020/03/08/813439501/saudi-arabia-stuns-world-with-massive-discount-in-oil-sold-to-asia-europe-and-u-

កុមារក្នុងគ្រួសារដែលមានចំណូលទាប អាចបោះបង់ការសិក្សាដោយមិនវិលត្រឡប់ទៅសាលាវិញ ព្រោះជីវភាពបានធ្លាក់ចុះ។គ្រួសារធូរធារអាចអនុវត្តបច្ចេកវិទ្យាអាចរក្សាការអប់រំបន្តប្រព័ន្ធឌីជីថលអនឡាញ។ នេះជាប្រភពមួយនៃការកើនឡើងនូវវិសមភាពក្នុងការទទួលបានការអប់រំ។

ការបិទទ្វាររយៈពេលវែងក៏អាចនឹងបង្កឱ្យបុគ្គលិកអប់រំមួយចំនួន បាត់បង់ការងារ និងចំណូលរបស់ពួកគេ។ សន្និសិទ សិក្ខាសាលា ដ៏មានអត្ថប្រយោជន៍ជាច្រើន សម្រាប់ទំនាក់ទំនងអាជីព វិទ្យាសាស្ត្រ នឹងត្រូវបាត់បង់វត្តមាន។

### ៣. ឥទ្ធិពលលើសង្គម

ការបង្ខាំងខ្លួនឆ្ងាយពីទំនាក់ទំនងសង្គម ការបាត់បង់ការងារ ការធ្លាក់ចុះនៃប្រាក់ចំណូល អាចបណ្តាលឱ្យមានស្ត្រេស អស់សង្ឃឹម ហិង្សាក្នុងគ្រួសារ ចោរកម្ម និងសកម្មភាពប្រាសចាកដ៏ទៃទៀត។

### ៤. ការឆ្លើយតប

ដើម្បីឆ្លើយតបនឹងភាពអវិជ្ជមានដែលកើតមានឡើងដោយសារកូវីដ១៩និងកត្តាដ៏ទៃទៀតត្រូវប្រើគ្រប់វិធានការណ៍ដែលអាចធ្វើបាន ដើម្បីគាស់សកម្មភាពធុរកិច្ចឱ្យបានប្រក្រតីឡើងវិញ។ការណ៍នេះអាចសម្រេចបានឆាប់រហ័សលុះត្រាមានកញ្ចប់ហិរញ្ញវត្ថុគាំទ្រវិស័យឯកជន។នៅប្រទេសអភិវឌ្ឍន៍ជាទូទៅធនាគារកណ្តាលបន្ធូបអត្រាការប្រាក់ សម្រាប់ដាស់ស្មារតីវិនិយោគ និងកញ្ចប់ចំណាយរបស់រដ្ឋដែលតម្រង់ទិសទៅរកៈ

- ការបង្កើតការងារ
- បន្ធូរបន្ថយបន្ទុកពន្ធ ដូចជាអាករលើតម្លៃបន្ថែមនិងពន្ធលើប្រាក់ចំណូល
- ឧបត្ថម្ភសហគ្រាសធុនតូចនិងមធ្យម (សហគ្រាសធុនតូចនិងមធ្យម)
- កម្ចីមានលក្ខណៈសម្បទាន
- លើកកម្ពស់សុខុមាលភាព និងស្មារតីបុគ្គល

### ៥. សន្និដ្ឋាន

ក្នុងសភាពមិនច្បាស់លាស់ នៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្មី ទាមទារភាពដឹកនាំរឹងមាំក្នុងសុខាភិបាល ធុរកិច្ច និងសង្គមកិច្ច។ វិធានការណ៍ស្តាឡើងវិញ ត្រូវអនុវត្តនិងកែតម្រូវតាមកាលៈទេសៈ សំដៅជួយតួអង្គទាំងឡាយដែលរងគ្រោះជាដំណាំ។ ការបង្កើតផែនការរយៈពេលមធ្យមនិងវែង គឺចាំបាច់សម្រាប់ផ្តល់ភាពអំណោយផលដល់សេដ្ឋកិច្ចដែលត្រូវមានតុល្យភាពឡើងវិញ និងមានថាមពលឡើងវិញ បន្ទាប់ពីមានវិបត្តិនេះ។ ផែនការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមទាំងមូល ត្រូវផ្តោតលើវិស័យនីមួយៗ ធុរកិច្ចនីមួយៗ ក្រុមមនុស្សដោយឡែកៗ ដោយបង្កើតបរិយាកាសអំណោយផល លើកទឹកចិត្តសហគ្រិនភាព ដែលធ្វើឱ្យក្រុមហ៊ុនរឹងមាំ ប្រជាពលរដ្ឋមានជំនឿជឿជាក់លើការរស់នៅ ការងារ និងរីកចម្រើនប្រកបដោយនិរន្តរភាព៕

**រៀបរៀងដោយ**

បណ្ឌិត **ម៉ម សារិទ្ធ** សមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង

បណ្ឌិត **ស៊ាង សុផល្លា** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ២- ប្រធានាធិបតី Donald Trump " ចោទប្រកាន់ប្រទេសចិន ដើម្បីរកលេសសម្រាលទំនួលខុសត្រូវការរីករាលដាល Covid-19 " ត្រូវឬខុស ?

ថ្មីៗនេះអ្នកនយោបាយខ្លះនៅក្នុងប្រទេសមួយចំនួនបានធ្វើការចោទប្រកាន់ថា ប្រទេសចិនគួរតែទទួលខុសត្រូវចំពោះការរាតត្បាតនេះដោយចោទប្រកាន់ប្រទេសចិនពីការបិទបាំងព័ត៌មានអំពីការផ្ទុះឡើងនៃ Covid-19។

ពួកគេតែងតែរិះគន់គេហៅថា កង្វះតម្លាភាពពីប្រទេសចិន។ ទោះយ៉ាងណាក៏ដោយអង្គហេតុនិយាយផ្ទុយពីនេះ។

កាលពីថ្ងៃទី ២៧ ខែធ្នូឆ្នាំមុនលោក Zhang Jixian គ្រូពេទ្យផ្លូវដង្ហើមនៅទីក្រុងវូហានដែលរងគ្រោះខ្លាំងជាងគេដោយសារការឆ្លងវីរុសនេះ គឺជាមនុស្សដំបូងបង្អស់ដែលជូនដំណឹងដល់អាជ្ញាធរអំពីជំងឺឆ្លងថ្មីបន្ទាប់ពីបានព្យាបាលអ្នកជំងឺដែលមានរោគសញ្ញាដូចជំងឺផ្តាសាយ។ទន្ទឹមនឹងនេះមន្ត្រីសុខាភិបាលទីក្រុងបានចាប់ផ្តើមការស៊ើបអង្កេតលើការរីករាលដាលនៃវីរុសនេះ។

ក្នុងរយៈពេលបីថ្ងៃគណៈកម្មការសុខភាពក្រុងវូហានបានធ្វើការជូនដំណឹងជាបន្ទាន់អំពីការផ្ទុះឡើងនៃជំងឺរលាកសួតនៃមូលហេតុដែលមិនស្គាល់នៅក្នុងទីក្រុងហើយបានចាប់ផ្តើមផ្សព្វផ្សាយព័ត៌មានសង្ខេបអំពីជំងឺនេះចាប់តាំងពីថ្ងៃទី៣១ ខែធ្នូ។

នៅពេលនោះនៅតែមានរាប់សិបថ្ងៃទៀតពីរបាយការណ៍ករណីដំបូងនៅសហរដ្ឋអាមេរិកនិងបណ្តាប្រទេសអឺរ៉ុបជាច្រើនដែលក្រោយមកត្រូវបានរងការវាយប្រហារដោយវីរុស។វាជាវីរុសដែលមិនស្គាល់សម្រាប់មនុស្សជាតិដែលត្រូវការពេលវេលាដើម្បីដឹងបន្ថែម។

ប៉ុន្តែប្រទេសចិនបានចាត់វិធានការយ៉ាងឆាប់រហ័សដើម្បីស៊ើបអង្កេតការផ្ទុះឡើងនេះ។ វាបានកំណត់អត្តសញ្ញាណប្រភពនិងផ្លូវបញ្ជូននៃជំងឺយ៉ាងឆាប់រហ័សហើយចែករំលែកព័ត៌មានដែលវាអាចទទួលបានទៅកាន់ពិភពលោកឱ្យបានឆាប់បំផុត។

ចាប់តាំងពីថ្ងៃទី៣ ខែមករា ប្រទេសចិនបានជូនដំណឹងជាទៀងទាត់ដល់អង្គការសុខភាពពិភពលោក (WHO) និងបណ្តាប្រទេសពាក់ព័ន្ធរួមទាំងសហរដ្ឋអាមេរិកផងដែរស្តីពីការវិវឌ្ឍន៍ចុងក្រោយនៃស្ថានភាពនេះ។

កាលពីថ្ងៃទី១២ ខែមករា ប្រទេសចិនបានចែករំលែកព័ត៌មានជាមួយអង្គការសុខភាពពិភពលោក (WHO) អំពីហ្សែននៃមេរោគថ្មីដែលបានដាក់មូលដ្ឋានគ្រឹះរឹងមាំសម្រាប់កិច្ចខិតខំប្រឹងប្រែងជាសកលនៃការស្រាវជ្រាវវិទ្យាសាស្ត្រនិងការបង្កើតវ៉ាក់សាំង។

នៅថ្ងៃទី២៣ ខែមករា ប្រទេសចិនបានដាក់វូហានចូលក្នុងការចាក់សោរ (lockdown) ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុស។ នៅពេលនោះទីក្រុងដែលមានប្រជាជនចំនួន ១១លាននាក់ បានរាយការណ៍ថាមានការឆ្លងតិចជាង ៥០០ករណី ខណៈដែលករណីនៅក្រៅប្រទេសមានតែ ៧នាក់ប៉ុណ្ណោះ។

មួយថ្ងៃក្រោយមកនៅក្នុងសារ Twitter ដំបូងរបស់គាត់ស្តីអំពី Coronavirus ប្រធានាធិបតីអាមេរិក Donald Trump បានកោតសរសើរប្រទេសចិនដែលបានខិតខំយ៉ាងខ្លាំងដើម្បីទប់ទល់នឹងវីរុសនេះ។ និយាយដោយយុត្តិធម៌ថា ប្រទេសចិនបានចាត់វិធានការគ្រប់ជ្រុងជ្រោយនិងតឹងរឹងបំផុតដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនេះតាមវិធីដែលអាចធ្វើទៅបាន។ រដ្ឋាភិបាលតែងតែសង្កត់ធ្ងន់ថា ព័ត៌មានអំពីការរាតត្បាតត្រូវតែរាយការណ៍ឱ្យបានទាន់ពេលវេលា និងត្រូវបានផ្សព្វផ្សាយដោយបើកចំហរ តម្លាភាព និងការពិត។

វិធានការណ៍របស់ប្រទេសចិន បានដំណើរការហើយជីវិតកំពុងវិលត្រឡប់មករកភាពប្រសើរឡើងវិញនៅក្នុងប្រទេសខណៈពេលដែលរោគរាតត្បាតនៅតែកំពុងបំផ្លិចបំផ្លាញនៅកន្លែងផ្សេងទៀត ដូច្នេះ ការជេរប្រមាថ និងការលាបពណ៌ប្រទេសចិនមិនល្អទេក្នុងការប្រយុទ្ធប្រឆាំងនឹងរោគរាតត្បាតមួយនេះ។

ជាការអត្ថាធិប្បាយរបស់ Xinhua បានចង្អុលបង្ហាញថាការវាយប្រហារដែលមានបរិមាណច្រើនប្រឆាំងនឹងប្រទេសចិន រួមទាំងការអំពាវនាវដែលមិនសមហេតុផល និងមិនត្រឹមត្រូវសម្រាប់ការសាកសួរបណ្តឹង និងសំណងដើម្បីធ្វើឱ្យប្រទេសចិនទទួលខុសត្រូវចំពោះការខូចខាតដោយវីរុស ដែលសុទ្ធសឹងតែជាការខិតខំប្រឹងប្រែងដើម្បីបង្វែរការយកចិត្តទុកដាក់ក្នុងស្រុកនិងការពារពួកគេនូវភាពអសមត្ថភាពផ្ទាល់ខ្លួននិងកំហុសឆ្គងក្នុងការពិនិត្យពិច័យ៕

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

**ព័ត៌មានពី ក.ស.វ.**

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) មានសេចក្តីរីករាយដោយលោកស្រី **ច្រុក ចន្ធី** មន្ត្រីនៅ ក.ស.វ. តាំងពីឆ្នាំ២០០៦ ទើបបានសម្រាលកូនស្រី កើតនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ឈ្មោះ **អួន ស្រីពេជ្រ** ។ ក.ស.វ. សូមជូនពរចំពោះមាតានិងបុត្រី ប្រកបដោយសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គល ព្រមទាំងពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## ៣- ជោគជ័យរបស់សម្តេចតេជោ ក្នុងការការពារកម្ពុជា ប្រយុទ្ធទប់ទល់នឹងមេរោគ Covid-19

បច្ចុប្បន្ន ពិភពលោកបានជួបប្រទះនឹងវិបត្តិដ៏ធ្ងន់ធ្ងរ ដែលអាចប្រៀបបានទៅនឹងសង្គ្រាមលោកលើកទី៣ ដោយសារតែការរាតត្បាតនៃជំងឺមេរោគកូរ៉ូណាថ្មីកូវីដ-១៩ ដែលបានសម្លាប់មនុស្សក្នុងពិភពលោកទាំងមូល ប្រមាណជាង៣០ម៉ឺននាក់ និងអ្នកមានអ្នករងជំងឺឆ្លងជាង ៤លាននាក់ ដែលក្នុងនេះប្រទេសអភិវឌ្ឍសេដ្ឋកិច្ចធំៗស្ទើរតែទាំងអស់សុទ្ធតែប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ក្នុងនោះមាន សហរដ្ឋអាមេរិក ចិន រុស្ស៊ី អ៊ីតាលី បារាំង អង់គ្លេស និងអេស្ប៉ាញ។

ក្នុងនាមជាអ្នកជាវិភាគ យើងគួរផ្តោតការវិនិច្ឆ័យលើចំណុច២៖ **ទី១**-បរិមាណនៃអ្នកឆ្លងនិងអ្នកស្លាប់ និងទំហំផ្ទៃប្រទេសនិងធាតុអាកាសនិងធនធានរបស់ប្ររទេសនិង**ទី២**-គឺចំណាត់ការរបស់អ្នកគ្រប់គ្រងប្រទេស។ ព្រោះជាទូទៅប្រទេសតូច ឬធំបច្ចុប្បន្នគឺជួបប្រទះនឹងបញ្ហាដូចគ្នា។

នរណាក៏ដឹងដែរថា មេរោគនេះចាប់កកើតដំបូងនៅទីក្រុងវ៉ូហាន ប្រទេសចិន នាចុងឆ្នាំ២០១៩ អ៊ីចឹងហើយបាន WHO ឲ្យឈ្មោះថា កូវីដ-១៩។

ឃើញសភាពការណ៍បែបអាសន្នយ៉ាងនេះមានប្រទេសមួយចំនួនបានប្រុងជើងប្រួលយ៉ាងម៉ឺងម៉ាត់និងហ្មត់ចត់ជាទីបំផុត ក្នុងនោះមានកម្ពុជាមួយផងដែរ ក្រោមការដឹងនាំដ៏ឆ្លាតវៃរបស់សម្តេចនាយករដ្ឋមន្ត្រី តេជោ **ហ៊ុន សែន** ។

សម្តេចបានចាត់វិធានការណ៍ទាន់ពេលវេលាក្នុងនោះបានបង្កើតគណៈកម្មាធិការជាតិមួយដែលសម្តេចបានសំរេចចិត្តធ្វើជាប្រធានដោយខ្លួនឯង ហើយបានចាត់វិធានការណ៍ផ្សេងៗជាបន្តបន្ទាប់ ក្នុងនោះមាន៖

**ទី១**-បានណែនាំឲ្យមន្ទីរពេទ្យទាំងអស់ក្នុងប្រទេសចាត់វិធានការណ៍ឲ្យបានហ្មត់ចត់ និងមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការពិនិត្យ ព្យាបាល និងតាមដានជំងឺមេរោគឆ្លងកូវីដ-១៩នេះ។

**ទី២**-ក្រសួងសុខាភិបាលដែលជាសេនាធិការរបស់គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ជាប្រចាំ និងផ្សព្វផ្សាយឲ្យបានទូលាយ ដើម្បីឲ្យស្ថាប័នរដ្ឋទាំងអស់ និងសាធារណជនទូទាំងប្រទេសបានជ្រួលជ្រាប ដើម្បីមានការប្រុងប្រយ័ត្នខ្ពស់។

**ទី៣**-ប្រព័ន្ធផ្សព្វផ្សាយ មានទូរទស្សន៍ សារព័ត៌មានជាដើម ត្រូវផ្សព្វផ្សាយព័ត៌មានអំពីលក្ខណៈនៃអាការៈរោគសញ្ញា និងវិធានការនានា ដោយរួមទាំងរបៀបការពារដែលប្រជាពលរដ្ឋម្នាក់ៗត្រូវយល់ឲ្យបានច្បាស់នូវវិបត្តិដែលមេរោគឆ្លងនេះ ដែលវាអាចនឹងញាំញីកំទេចគ្រួសារ និងសង្គមជាតិទាំងមូល។

**ទី៤**-បានណែនាំដល់គ្រឹះស្ថានរដ្ឋ ក្រសួងមន្ទីរ បែងចែកកាលវិភាគការងារ មិនឲ្យធ្វើការកកកុញណែនណាន់គ្នា។ អ្នកធ្វើការត្រូវមានស្មារតី យកពេលទំនេរចុះមូលដ្ឋានអប់រំប្រជាជន គណៈដឹកនាំភូមិ ឃុំ ស្រុក ខេត្ត ឲ្យបានយល់ជ្រួតជ្រាបពីវិធានការណ៍ការពារខ្លួន និងវិធានការណ៍ប្រុងប្រយ័ត្នកម្រិតខ្ពស់។

**ទី៥**-នាពេលថ្មីៗនេះទៀតសោតសម្តេចបានចាត់វិធានការណ៍បន្ថែមទៀតក្នុងស្មារតីទទួលខុសត្រូវជួយធានាដល់សុខមាលភាពពលករដែលធ្វើចំណាកស្រុកពីកូរ៉េម៉ាឡេស៊ីពិសេសពីប្រទេសថៃពេលដែលប្រទេសនេះកំពុងជួបវិបត្តិធ្ងន់ធ្ងរនឹងរោគកូវីដ-១៩ដែរនោះ។ថៃបានបានរុញពលករខ្មែរឲ្យធ្វើមាតុភូមិវិវត្តន៍វិញស្ទើរតែទាំងអស់ដែលនេះជាបញ្ហាដ៏ចម្បងមួយទៀតគឺការបារម្ភពីការឆ្លងមេរោគពីខាងក្រៅចូលមកក្នុងប្រទេស។ក្នុងន័យនេះរាជរដ្ឋាភិបាលបានចាត់វិធានការណ៍យ៉ាងលំអិត ដូចតទៅ៖

**ក**-រៀបចំយានយន្តដឹកជញ្ជូនធំៗជាច្រើនរយគ្រឿងមិនឲ្យពលករធ្វើដំណើររហោតរហូត

**ខ**-រៀបចំសណ្ឋាគារ ឬកន្លែងស្នាក់នៅជាច្រើនសម្រាប់ដាក់ពលករឲ្យរស់ស្នាក់នៅ ដោយឡែក(Quarantine-ចត្តាឡីស័ក)បាន១៤ថ្ងៃនិងបានផ្តល់អាហារនិងការថែទាំសុខភាពដល់ពលករទាំងអស់នោះផងដែរ។

ក្នុងន័យនេះ រដ្ឋាភិបាលបានចំណាយថវិការជួយយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការជួយពលកររាប់ម៉ឺននាក់ទាំងអស់នោះ ដែលធ្វើដំណើរមកយ៉ាងគំហុកបែបនេះ ដើម្បីបុព្វហេតុតែមួយគត់ គឺធ្វើយ៉ាងណាចៀសវាងការឆ្លងមេរោគកូវីដ-១៩តៗគ្នា ក្នុងគ្រួសារនិងសង្គមជាតិទាំងមូល។

**ទី៦**-ចំពោះទីផ្សារវិញ រាជរដ្ឋាភិបាលបានអំពាវនាវដល់អាជីករ អ្នកលក់ដូរផ្សារ មិនឲ្យធ្វើវិច្ឆេទកម្មលើវិបត្តិនៃមេរោគឆ្លងកូវីដ-១៩នេះ មិនឲ្យស្តុកទុកផលិតផលការពារ ដូចជាម៉ាសពាក់មុខ (Mask) អាល់កុលជូតសំអាតដៃជាដើម។ល។

**ទី៧**-បានចេញបញ្ជាឲ្យផ្អាកការសិក្សាជាបណ្តោះអាសន្នគ្រប់គ្រឹះស្ថានសិក្សា សារៈមន្ទីរ ក្លឹបកំសាន្ត ការដើរកំសាន្តនាពិធីបុណ្យចូលឆ្នាំ។ល។ ពិសេសដំណើរចេញក្រៅផ្ទះដោយមិនចាំបាច់ ដើម្បីការពារការឆ្លងជំងឺពីគ្នាទៅវិញទៅមកជាយថាហេតុ។

**ទី៨**-វិធានការណ៍ពិសេសមួយទៀត គឺទប់ទល់នឹងការឆ្លងមេរោគតាមរយៈអ្នកទេសចរណ៍ និងអ្នកដំណើរដែលមកប្រទេសកម្ពុជាតាមយន្តហោះ។ក្នុងនោះបានធ្វើការត្រួតពិនិត្យនិងចំរាញ់យ៉ាងហ្មត់ចត់ពិសេសអ្នកដំណើរមកពីប្រទេសដែលមានវិបត្តិមេរោគឆ្លងច្រើនដោយមានការដាក់Quarantine១៤ថ្ងៃនិងជួយព្យាបាលអ្នកដំណើរដែលមានជំងឺឆ្លងមេរោគនេះ ហើយដោយពុំយកតម្លៃសេវារហូតដល់បានជាសះស្បើយ។

**ទី៩**-រាជរដ្ឋាភិបាលបានចេញប្រកាសមិនឲ្យបរទេសដែលមានសញ្ជាតិប្រទេសដែលរងគ្រោះច្រើនជាងគេចូលមកប្រទេសខ្មែរ ក្នុងនោះមាន៖ បារាំង អង់គ្លេស អេស្ប៉ាញ អ៊ីតាលី អ៊ីរ៉ង់ និងសហរដ្ឋអាមេរិករហូតដល់មានបទបញ្ជាជាថ្មី។

ទន្ទឹមនឹងនេះបេះដូងមនុស្សធម៌សម្តេច បានអនុញ្ញាតឲ្យនាវា Westerdam ដែលជាក្រុមហ៊ុនសហរដ្ឋ-អាមេរិកដឹកអ្នកទេសចរណ៍ ២២៥៧នាក់ រួមមាន ៤១ជនជាតិសាសន៍ ដែលបានរសាត់អណ្តែតលើផ្ទៃមហាសមុទ្រសាគរគ្មានកោះត្រើយ ចូលចតនៅកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ គឺបន្ទាប់ពីនាវានេះត្រូវបានបណ្តាកោះ ប្រទេសជប៉ុន កូរ៉េខាងត្បូង ហ្វីលីពីន ថៃ កោះហ្គាំ(សហរដ្ឋអាមេរិក)និងអាជ្ញាធរតៃវ៉ាន់ បានផាត់ពុំឲ្យចូលចតព្រោះតែខ្លាចឆ្លងជំងឺកូវីតនេះ។

ចំពោះទឹកចិត្តមនុស្សធម៌ដ៏ប្រពៃថ្លៃថ្លារបស់សម្តេច បានធ្វើឲ្យរំជួលចិត្តដល់ប្រជាជាតិនានាលើភពផែនដីមេដឹកនាំលើពិភពលោកទាំងតូចទាំងធំពិសេសប្រធានាធិបតីសហរដ្ឋអាមេរិកលោកដូណាល់ត្រាំបានបង្ហោះសារតាម Twiter ផ្ទាល់ខ្លួនដ៏មានអត្ថន័យថា «សូមអរគុណប្រទេសកម្ពុជាដ៏ស្រស់បំព្រង និងថាសហរដ្ឋអាមេរិកនឹងចងចាំអំពើល្អរបស់កម្ពុជា»។

ចំពោះចំណាត់ការដ៏ហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា បានឃើញលទ្ធផលជាក់ស្តែង៖ **ទី១**-អ្នកជំងឺដែលឆ្លងរោគមានចំនួនតិចបំផុតគឺ ១២២ករណី **ទី២**-បានព្យាបាលជាអស់ទាំងចំនួន ១២២នាក់ជាស្ថាបពរ និង**ទី៣**-មិនឃើញមានអ្នកជំងឺដែលឆ្លងមេរោគកូវីដថ្មីៗនេះទៀតឡើយ។

ជាសរុប គេគួរវាយតម្លៃខ្ពស់ទៅលើភាពប្រាកដនិយមរបស់ប្រមុខរាជរដ្ឋាភិបាលដែលបានយល់សភាពការណ៍នឹងទប់ស្កាត់វិបត្តិមេរោគទាន់ពេលវេលាពិសេសបានចាត់វិធានការណ៍ប្រកបដោយសុភវិនិច្ឆ័យដោយឈរលើស្មារតីកម្ពុជាជាប្រទេសតូចមានធនធានស្តួចស្តើងតែមានស្មារតីទទួលខុសត្រូវខ្ពស់!ដោយឡែកចំពោះប្រទេសមហាអំណាចសេដ្ឋកិច្ចដែលសំអាងថាខ្លួនជាប្រទេសធំមានធនធានមហាសាលតែបើអ្នកដឹកនាំខ្វះសុភវិនិច្ឆ័យ និងទេពកោសល្យទទួលខុសត្រូវ ធ្វើសេចក្តីសម្រេចមិនសូវចំទិសដៅ គឺនោះហើយជាកត្តាដែលពិភពលោកកំពុងជួបប្រទះនឹងវិបត្តិដ៏ធ្ងន់ធ្ងរនាបច្ចុប្បន្ន ! ៕

ដោយ វ័ត្ន សណ្តាប់

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី ឃឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមីនាឆ្នាំ២០២០ |
|---|---|---|
| ១ | ០២/៣/២០<br>ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២ | ០៤/៣/២០<br>ម៉ោង០៨:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីអបអរសាទរខួបលើកទី១០៩ នៃទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ "មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៤/៣/២០<br>ម៉ោង១៤:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទអង្គសន្និបាតបូកសរុបការងារសុខាភិបាលប្រចាំឆ្នាំ២០១៩ លើកទី៤១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។ |
| ៤ | ០៥/៣/២០<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំ ស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០២០ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/៣/២០<br>ម៉ោង១៥:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ី សារី** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តី-ការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៦/៣/២០<br>ម៉ោង០៨:៣០នាទី | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី១០៩ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ "មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ៧ | ០៧/៣/២០<br>ម៉ោង០៨:០០នាទី | ចូលរួមជាអធិបតី ក្នុងពិធីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា ឆ្នាំ២០២០ នៅវត្តអង្គអណ្តែត ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៨ | ១០/៣/២០<br>ម៉ោង០៧:២០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត វិទ្យាស្ថាន វ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ៩ | ១០/៣/២០<br>ម៉ោង១៥:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាល និងប្រគល់ប្រាក់រង្វាន់ជ័យលាភី និងប្រាក់ឧបត្ថម្ភដល់គ្រូបង្វឹក គ្រូជំនួយ កីឡាករ កីឡាការិនីជម្រើសជាតិកម្ពុជា ដែលទទួលបានមេដាយក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅប្រទេសហ្វីលីពីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ១០ | ១១/៣/២០<br>**ម៉ោង០៨:០០នាទី** | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីប្រារព្ធទិវាជាតិអំណានលើកទី៥ ក្រោមប្រធានបទ "ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍" ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ១១ | ១២/៣/២០<br>**ម៉ោង០៩:០០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **នរ៉ាណារិទ្ធិ អានន្ទយ៉ាត** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៨/៣/២០<br>**ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **នរ៉ាណារិទ្ធិ អានន្ទយ៉ាត** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៨/៣/២០<br>**ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ឆយ អូន** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៩/៣/២០<br>**ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ញឹក ចណ្ណារ៉ា** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២០/៣/២០<br>**ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ខិន ទីរៈ** ឯកឧត្តម **រ័ត្ន សណ្តាប់** និងឯកឧត្តម **ភយ ប៊ុរី** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៣/៣/២០<br>**ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឡុង គែម** និងឯកឧត្តម **ហែម ហេង** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៦/៣/២០<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែមេសាឆ្នាំ២០២០** |
|---|---|---|
| ១ | ៣០/៤/២០<br>**ម៉ោង០៨:៣០នាទី** | ចូលរួមជាអធិបតី ក្នុងកម្មវិធីផ្តល់ជំនួយសម្ភារៈបរិក្ខារបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកព្រៃកប្បាស ជូនដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរបង្អែកស្រុក មណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ នៃស្រុកព្រៃកប្បាស នៅស្នាក់ការស្រុកព្រៃកប្បាស ខេត្តតាកែវ។ |

| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែឧសភាឆ្នាំ២០២០** |
|---|---|---|
| ១ | ០៧/៥/២០<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១១/៥/២០<br>**ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១១/៥/២០<br>**ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **នរ៉ាណារិទ្ធិ អានន្ទយ៉ាត** ឯកឧត្តម **ប៊ិច សុខា** និងសហការី នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១២/៥/២០<br>**ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំត្រីមាសទី១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៥ | ១៣/៥/២០<br>ម៉ោង០៩:០០នាទី | ដឹកនាំអង្គប្រជុំដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្ដីព្រាងច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ<br>២- បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដី-ការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៥/៥/២០<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្ដីព្រាងច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម<br>២- សេចក្ដីព្រាងច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ<br>៣- សេចក្ដីព្រាងច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ<br>៤- បញ្ហាផ្សេងៗ សុំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ<br>លើ៖<br>៤.១- សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងម៉ាឡេស៊ី<br>៤.២- សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការលប់បំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ<br>៤.៣- សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាទីក្រុងប៊ែន ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ និងវិសោធកម្មឆ្នាំ១០៧៩។ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៨/៥/២០<br>ម៉ោង១៥:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក.ស.វ. នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ២០/៥/២០<br>ម៉ោង០៧:៣០នាទី | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីហែនិងបូជាសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស នៅមុខវត្តបទុមវតី រាជធានីភ្នំពេញ។ |
| ៩ | ២៦/៥/២០<br>ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទយ៉ាត** និងសហការី នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២៦/៥/២០<br>ម៉ោង១១:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **យូ ស៊ានឡុង** នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ២៨/៥/២០<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

## ពន្យល់ពាក្យ

**វ័យ** ន. : គឺជាដំណើរសូន្យទៅខាងក្រោយ លឿនទៅខាងមុខ គឺអាយុ។
វ័យជីវិតមនុស្សមាន១០យ៉ាង៖

| | | | |
|---|---|---|---|
| ១- មន្ទទសក : | (ពី១ - ១០ឆ្នាំ) | = | វ័យស្រួយ |
| ២- ទិន្ទទសក : | (ពី១១ - ២០ឆ្នាំ) | = | វ័យល្បែង |
| ៣- វណ្ណទសក : | (ពី២១ - ៣០ឆ្នាំ) | = | វ័យល្អ |
| ៤- ពលទសក : | (ពី៣១ - ៤០ឆ្នាំ) | = | វ័យខ្លាំង |
| ៥- បញ្ញាទសក : | (ពី៤១ - ៥០ឆ្នាំ) | = | វ័យពិចារណា |
| ៦- ពោធិទសក : | (ពី៥១ - ៦០ឆ្នាំ) | = | វ័យទន់ |
| ៧- បញ្ហារទសក : | (ពី៦១ - ៧០ឆ្នាំ) | = | វ័យជរា |
| ៨- វង្កាទសក : | (ពី៧១ - ៨០ឆ្នាំ) | = | វ័យកោង |
| ៩- មោបូហទសក : | (ពី៨១ - ៩០ឆ្នាំ) | = | វ័យភ្លេច |
| ១០- សយនទសក : | (ពី៩១ - ១០០ឆ្នាំ) | = | វ័យដេក |

**លម្អ** ន. : គឺជាបែបភាព បែបបទ លំនាំ។
កិរិយាដែលលម្អមាន៤យ៉ាង៖

| | | |
|---|---|---|
| ១- លម្អនៃតារ៉ៅ | : | គឺ សំលេងពិរោះ |
| ២- លម្អនៃស្រ្តី | : | គឺ ភក្តីភាព |
| ៣- លម្អនៃបុរស | : | គឺ ចំណេះវិជ្ជា |
| ៤- លម្អនៃបព្វជិត | : | គឺ ខន្តី |

**កវី** ន. : គឺអ្នកថ្លែងកាព្យ អ្នកនិពន្ធកំណាព្យ មាន៤យ៉ាង៖

| | | |
|---|---|---|
| ១- ចិន្តកវី | = | និពន្ធដោយគំនិត |
| ២- សុតកវី | = | និពន្ធដោយបានឮបានស្តាប់ |
| ៣- អត្ថកវី | = | និពន្ធសេចក្តីពិត |
| ៤- បដិភាណកវី | = | និពន្ធកាព្យសុទ្ធៗ |

## ស្រាវជ្រាវ : យល់ដឹងអំពីពាក្យ " កូសាំងស៊ីន "

ទីតាំងភូមិសាស្រ្តកូសាំងស៊ីនសម្គាល់ទឹកដីកម្ពុជាក្រោមដែលមានប្រជាជនខ្មែររស់នៅជាងប្រាំបីលាននាក់។ បច្ចុប្បន្នពាក្យកូសាំងស៊ីន ពុំបានមានវត្តមាននៅលើទំព័រអត្ថបទនិពន្ធទៀតទេ ប៉ុន្តែពាក្យនេះ អ្នកសិក្សាស្រាវជ្រាវរមែងជួបប្រទះក្នុងឯកសារប្រវត្តិសាស្រ្តកម្ពុជាដែលសរសេរឡើងដោយអ្នកប្រាជ្ញអឺរ៉ុបនិងបារាំងក្នុង គ.ស.វ.ទី១៩ និងដើមគ.ស.វ.ទី២០។ ស្មេរសាកល្បងសិក្សាពាក្យ កូសាំងស៊ីន ក្នុងគោលបំណងបកស្រាយចម្ងល់អ្នកអានមួយចំនួនដែលចង់ដឹងពីឫសគល់នៃពាក្យនេះតែប៉ុណ្ណោះ។

តើយើងអាចសាកល្បងកំណត់ កាលបរិច្ឆេទនៃកំណើតពាក្យកូសាំងស៊ីនបានដែរឬទេ ?

**ក. ចំពោះខ្មែរយើង** : មិនមានអ្វីបញ្ជាក់ជាប្រាកដថា មានពាក្យនេះនៅសម័យណាទេ តែយើងអាចសន្និដ្ឋានថាយើងប្រទះពាក្យនេះនៅក្រោយពេលបារាំងចូលមកត្រួតត្រាហើយ។លើកលែងតែសៀវភៅដែលសរសេរដោយជនជាតិអឺរ៉ុបនិងបារាំង យើងកម្រនឹងប្រទះពាក្យ "កូសាំងស៊ីន" នៅក្នុងសៀវភៅខ្មែរណាស់។ ចំពោះខ្មែរពាក្យនេះមានប្រើបន្ទាប់បន្សំតែក្នុងការនិយាយប៉ុណ្ណោះឯក្នុងសំណេរវិញយើងប្រើពាក្យកម្ពុជាក្រោមវិញទេ។

**ខ. ចំពោះឯកសារបរទេស** : ផ្ទុយទៅវិញពួកអឺរ៉ុបមានប្រើពាក្យកូសាំងស៊ីន ចាប់តាំងពីដើមស.វ.ទី១៦ម្ល៉េះ។ ក្នុងពេលនោះ យួនធ្វើការលាតសន្ធឹងអំណាចមកដល់ត្រឹមតំបន់ Qui Nhon ( ស្ថិតនៅក្រោម Binh-Dinh ក្នុងអណ្ណាមកណ្តាល ) ឯដីសណ្តនៃទន្លេមេគង្គនៅជាដីខ្មែរនៅឡើយ។ ប៉ុន្តែយើងត្រូវកត់សម្គាល់ថា ពួកអឺរ៉ុបបានប្រើពាក្យនេះ សំដៅទៅលើតំបន់ផ្សេងៗក្រៅពីកម្ពុជាក្រោម។

*** ការប្រើពាក្យកូសាំងស៊ីន នៅរវាងចន្លោះឆ្នាំ១៥០២-១៦១៥ :**

គេជួបប្រទះពាក្យ កូសាំងស៊ីន (សរសេរជា chinacochin) ជាដំបូងនៅឆ្នាំ១៥០២ នៅលើផែនទីរបស់ពួកព័រទុយហ្គេ។ ជនជាតិហ្សែន (gênes) ម្នាក់ឈ្មោះ Alber Contino បានរៀបចំផែនទីនេះឡើង ដោយបានប្រើពាក្យChinacochinសំដៅកំពង់ផែសមុទ្រមួយដែលមានទីតាំងនៅលើដីសណ្តនៃទន្លេក្រហមនៅយួនតុងកឹងសព្វថ្ងៃ។ ចុះមកខាងត្បូងនៅត្រង់មុំប្រទេសចាម្ប៉ា លោក Contino បានចារឹកកំពង់ផែមួយទៀតឈ្មោះ Champacochin ។

នៅឆ្នាំ១៥១៥ Albuquerque ជាជនជាតិព័រទុយហ្គេ បានមកដល់កំពង់ផែ កាលីគុត (Calicut) នៃប្រទេសឥណ្ឌា ហើយបានផ្ញើរសារលិខិតមួយទៅឲ្យស្តេចរបស់ខ្លួន។ ក្នុងលិខិតនោះ Albuquerque បានធ្វើសេចក្តីរាយការណ៍ពីជំនួញដែលគ្រឹះស្ថានព័រទុយហ្គេនៅឥណ្ឌាបានធ្វើជាមួយនឹងអាស៊ីបូព៌ាដោយមានរៀបរាប់ឈ្មោះរាជាណាចក្រជាច្រើន ដូចជា ហង្សាវតី ចិន សៀម...និង Quachynchyna ជាដើម។ ក្នុង Quachynchyna ប្រហែលជាសំដៅទៅលើតំបន់ អណ្ណាម( យួនកណ្តាល ) មិនមែនទៅលើតុងកឹងទេ។ នៅពេលនោះ យួនបានវាយយកបានដីចាម្ប៉ា រហូតមកដល់ជ្រោយ Verella ហើយ។

នៅរវាងឆ្នាំ១៥២៩-១៦១៣ ផែនទីដទៃទៀតរបស់ពួកអឺរ៉ុបបានប្រើពាក្យ Cauchechina សំដៅសរុបទៅលើប្រទេសយួនទាំងមូល( តុងកឹងហើយនិងអណ្ណាម )។

សម្គាល់៖ ប្រសិនបើយើងក្រឡេះមកពាក្យ Chinacochin នឹងបានទៅជា Cauchechina ។ មុនឆ្នាំ១៥១៥ ពួកនាវិកព័រទុយហ្គេ មិនទាន់មកដល់ឧបទ្វីបឥណ្ឌូចិននៅឡើយ។ ពួកនេះស្គាល់ឥណ្ឌូចិនតាមរយៈពួកអារ៉ាប់តែប៉ុណ្ណោះ ដូចនោះហើយបានជាគេមិនអាចសរសេរឈ្មោះស្រុកនីមួយៗឲ្យបានត្រឹមត្រូវឡើយ។ ម្យ៉ាងវិញទៀត ពាក្យ cochin ប្រហែលមានន័យទូទៅថាកំពង់ផែ។

*** ការប្រើពាក្យកូសាំងស៊ីន នៅរវាងចន្លោះឆ្នាំ១៦១៥-១៨៨២ :**

នៅរវាងឆ្នាំ១៦១៨ ក្នុងអត្ថបទ" Relation de la Nouvelle mission au royaume de cochinchine" (អត្ថបទចុះផ្សាយក្នុង Revue indo chinoise t.XI នៅឆ្នាំ១៩០៩) លោកសង្ឃផ្សាយសាសនាគណៈ Jésuite ឈ្មោះ Christophore Borri បានសន្មតពាក្យកូសាំងស៊ីននេះ សំដៅទៅលើប្រទេសយួនផ្នែកកណ្តាល ហៅថា អណ្ណាម (ឬអតីតចម្ប៉ាមួយផ្នែកធំ)។ ពេលនោះ អណ្ណាម ជាក្សត្រប្រទេស (principauté) ដែលមានរាជវង្ស Nguyên គ្រប់គ្រង។

លោកសង្ឃBorriបានបញ្ជាក់ទីតាំងរាជាណាចក្រកូសាំងស៊ីន(អណ្ណាម)យ៉ាងច្បាស់ថា ខាងត្បូងមានព្រំប្រទល់ជាប់នឹងប្រទេសចាម្ប៉ា (Champa) ខាងជើងជាប់នឹង តុង កឹង (Tmuchin) ប្រទេសលាវ (Lai) ខាងកើតជាប់នឹងសមុទ្រចិន។ នៅសវ.ទី១៧ ប្រទេសយួនចែកចេញជារាជាណាចក្រពីរៈ

- ខាងជើងប្រទេស តុង កឹង របស់រាជវង្ស Trinh ដែលមានរាជធានីនៅ ហាណូយ(Hanoi)។
- ខាងត្បូងប្រទេស អណ្ណាម របស់រាជវង្ស Nguyên ដែលមានរាជធានីនៅ ហ្វេ (Hué)។ រាជាណាចក្រពីរនេះច្បាំងគ្នាជាប់ជានិច្ច។

រហូតមកដល់ឆ្នាំ១៨៨២ពួកអឺរ៉ុបបានប្រើពាក្យកូសាំងស៊ីនសម្រាប់សំដៅសម្គាល់ទៅលើក្សត្រប្រទេសនៃរាជវង្ស ង្វៀន តែមួយប៉ុណ្ណោះ។ ប៉ុន្តែយើងត្រូវកត់ចំណាំថា ក្សត្រប្រទេសនេះមាន " ដំណើរសម្រុកចុះមកក្រោម" គឺមកខាងត្បូងជានិច្ច ហើយបន្តិចម្តងៗក៏បានរាតអំណាចលើប្រទេសចាម្ប៉ានិងលើកម្ពុជាក្រោមទាំងមូល។ ទំហំផ្ទៃដីនិងទីតាំងភូមិសាស្ត្ររបស់រាជាណាចក្រកូសាំងស៊ីន ក៏រីកទូលាយតាម"ដំណើរសម្រុកចុះមកក្រោម" នេះដែរ។ យើងសូមបញ្ជាក់ថា យួនបានត្រួតត្រាទឹកដីចាម្ប៉ាទាំងមូលនៅឆ្នាំ១៦៩៦ និងទឹកដីកម្ពុជាក្រោមនៅឆ្នាំ១៨៤០។

ជាមួយគ្នានឹងនយោបាយពង្រីកទឹកដី រាជវង្ស ង្វៀន បានទាក់ទាញពួកព័រទុយហ្គេ ដែលមានគ្រឹះស្ថានជំនួញនៅគណ្ឌា និងនៅ Insulinde ឲ្យមកធ្វើជំនួញ។ ដោយបានទទួលការទំនុកបម្រុងជាគ្រឿងសព្វាវុធ (កាំភ្លើងនិងគ្រាប់រំសេវ) រាជវង្ស ង្វៀន បានយកជ័យជម្នះលើរាជវង្ស ទ្រិញ ហើយបានបង្រួបបង្រួមប្រទេសយួនទាំងមូលឲ្យមានឯកភាព។ ដូចនោះហើយបានជានៅឆ្នាំ១៨៤០ គេក៏ចាប់ផ្តើមប្រើពាក្យ វៀតណាម សំដៅទៅលើដែនដីដែលយួនកាន់កាប់ទាំអស់ គឺចាប់ពីព្រំដែនចិននៅខាងជើងរហូតមកដល់កម្ពុជាក្រោម។

ជនជាតិបារាំងបានផ្តើមចូលមកកាន់កាប់ដីកម្ពុជាក្រោម ចាប់ពីឆ្នាំ១៨៦១ ហើយក៏បានចែកសម្គាល់ប្រទេសយួន ជាតំបន់ដែលខ្លួនបានកាន់កាប់ហើយ ពីតំបន់មិនទាន់ត្រួតត្រាគឺៈ

- ប្រទេសខាងជើង ហៅ តុង កឹង ឬ Bac Ky
- តំបន់កណ្តាល ហៅ អណ្ណាម (អតីតចាម្ប៉ា) ឬកូសាំងស៊ីន ឬ Trung Ky។ តំបន់ទាំងពីរនេះ បារាំងមិនទាន់បានកាន់កាប់នៅឡើយទេ។
- ប្រទេសខាងត្បូង ហៅ កូសាំងស៊ីនក្រោម (Bass Cochinchine ou Cochinchine française ឬ Nam Ky)។ តំបន់នេះជាអាណាខេត្តទាំងឡាយនៃកម្ពុជាក្រោម ដែលបារាំងវាយដណ្តើមយកពីយួននៅស.វ.ទី១៩។ ពេលនោះ បារាំងកាន់កាប់ខេត្តចង្វាត្រពាំងស្រកាត្រី ខេត្តព្រៃនគរ និងខេត្តមេ ស នៅឆ្នាំ១៨៦២ ខេត្តលង់ហោ ខេត្តមាត់ជ្រូក និងខេត្តពាម នៅឆ្នាំ១៨៦៧។

*** ការប្រើពាក្យកូសាំងស៊ីន ពីឆ្នាំ១៨៨៧ រៀងមក :**

បារាំងបានត្រួតត្រាលើប្រទេសយួនទាំងមូល ហើយចាប់ពីឆ្នាំ១៨៨៧ បានចែកប្រទេសនេះជា៣តំបន់ដាច់ពីគ្នាដដែលគឺ៖

- តុង កឹង
- អណ្ណាម
- កូសាំងស៊ីនក្រោម ឬកូសាំងស៊ីនបារាំង ឬកូសាំងស៊ីន (កម្ពុជាក្រោម)។

អ្នកនិពន្ធជាច្រើន បានសាកល្បងពន្យល់ រកឫសកំណើតនៃពាក្យកូសាំងស៊ីន៖

**១. មតិខ្មែរយើងទូទៅយល់ថា :**

ពាក្យនេះក្លាយមកពីពាក្យ កូជិនស៊ីន ដែលអាចមានកំណើតនៅស.វ.ទី១៧ គឺក្នុងរជ្ជកាលស្តេចជ័យជេដ្ឋាទី២។ ពេលនោះខ្មែរយើងចាប់ផ្តើមមានទំនាក់ទំនង ជាមួយនិងយួនជាលើកដំបូងដោយចំណងមង្គលការ គឺជាមួយក្សត្រប្រទេសនៃរាជវង្ស ង្វៀន ដែលតាំងរាជធានីនៅ ហ្វេ ហើយដែលបានត្រួតត្រាប្រទេសចាម្ប៉ា និងមានព្រំប្រទល់នឹងខេត្តខ្មែរនៅកម្ពុជាក្រោម។ ក្នុងគោលបំណងបន្ថយឥទ្ធិពលរបស់សៀម មកលើប្រទេសខ្មែរ ស្តេចជ័យជាដ្ឋាទី២ បានងាកទៅរកសម្ពន្ធមេត្រីនឹងយួន។ ស្តេចអង្គនេះបានទទួលកូនស្រីទី៨របស់ស្តេចយួនឈ្មោះ ក្សត្រីអង្គចូវ ជាមហេសី ។ ដោយសារមានចំណងគ្រួសារ ដូចនេះ បានជានៅឆ្នាំ១៦២៣ស្តេចខ្មែរបានសុខចិត្តប្រគល់ដី កោះក្របី ព្រៃនគរ ដែលយួនហៅថា Bên Ngné តាមពាក្យស្តេចយួនសុំខ្ចីបង្ហាត់ទាហាននិងយកពន្ធដារក្នុងរយៈពេល៥ឆ្នាំ។មេទ័ពយួនម្នាក់ក៏ត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវលើព្រៃនគរ ហើយនិគមជនយួនក៏ចាប់ផ្តើមតាំងទីលំនៅក្នុងដីខ្មែរ។នេះគឺជាការផ្តើមតាំងទីលំនៅ និងរាតអំណាចយួនមកលើដីកម្ពុជាក្រោម។ បន្តិចម្តងៗខេត្តខ្មែរក៏ត្រូវបាត់បង់ជាបន្តបន្ទាប់គ្នា៖

- ខេត្ត ព្រះសួគ៌ានិងខេត្តចង្វាត្រពាំងស្រកាត្រី នៅឆ្នាំ១៦៥៨
- ខេត្ត ព្រៃនគរ នៅឆ្នាំ១៦៩៦
- ខេត្ត ពាមនិងខេត្តក្រមួនស នៅឆ្នាំ១៧៣៩
- ខេត្ត ផ្សារដែកនិងខេត្តមាត់ជ្រូក នៅឆ្នាំ១៧៧៥
- ខេត្ត ឃ្លាំងនិងខេត្តទឹកខ្មៅ នៅឆ្នាំ១៨៤០
- ខេត្ត លង់ហោនិងខេត្តមេ ស នៅឆ្នាំ១៩៣១

ដូចនេះហើយបានជាកើតមានពាក្យ កូនជិនស៊ីន នេះឡើងគឺ ៖ កូនជិន=កូនស្រីទី៩+ស៊ីន=សុំ បានសេចក្តីថា ដីដែលកូនស្រីទី៩ នៃស្តេចហ្វេសុំយកទៅ។ ប៉ុន្តែមានមិតិខ្លះថា ក្សត្រីយួននេះឈ្មោះ ជិន ទេ តែក្នុងឯកសារខ្មែរយើងគ្មានបាននិយាយពីឈ្មោះ ជិន នេះទាល់តែសោះ។ យើងអាចសាកល្បងពន្យល់បញ្ហានេះដូចតទៅ៖ យោងទៅតាមទម្លាប់ក្នុងគ្រួសាររបស់យួន គេមិនបានទុកកូនច្បងជាកូនទី១ ដូចខ្មែរយើងឡើយ គឺគេទុកជាកូនទី២។ ដូចនេះ គេចាប់រាប់ជាកូនទី២ កូនទី៣ កូនទី៤ កូនទី៥ កូនទី៩ (=កូនទី៨) រៀងទៅ។ ធម្មតាក្នុងការនិយាយគ្នាក្នុងគ្រួសារ គេពុំសូវហៅឈ្មោះកូនទេ គេនិយមហៅតាមលេខរៀងគឺបើកូនស្រីទី៨គេហៅថាកូនជិន (កូ=កូនស្រី, ជិន=៩)។

ទោះជាការពន្យល់ឫសកំណើតរបស់ពាក្យកូជិនស៊ីននេះមានលក្ខណៈសមរម្យក៏ដោយ ក៏គួរយើងកត់សម្គាល់ថា ពាក្យនេះបានសាយភាយទៅដល់ទ្វីបអឺរ៉ុបតាំងពីឆ្នាំ១៥០២ម្ល៉េះ (ផែនទីរបស់លោកAlbert Contino)។ ឯពាក្យស្តេចជ័យជេដ្ឋាទី២ ដែលយើងសន្មត់ថា ជាកាលបរិច្ឆេទនៃកំណើតពាក្យស្ថិតនៅចន្លោះ

ឆ្នាំ"១៦១៧-១៦២៧"គឺនៅដើមសតវត្សទី១៧។នៅសតវត្សទី១៧នេះឯកសារបរទេសដែលយើងបានរៀបរាប់មកហើយនោះ បានចាត់ទុកកូសាំងស៊ីនជាក្បត្រប្រទេសនៃរាជវង្ស ង្វៀន ដែលមិនទាន់វាយយកដីចាម្ប៉ាបានទាំងមូលនៅឡើយ ឯកម្ពុជាក្រោមវិញនៅជាទឹកដីរបស់ខ្មែរ។

ដូចនេះ ប្រសិនបើយើងមិនទាន់បានជួបប្រទះពាក្យ កូជិនស៊ីន ឬពាក្យ កូសាំងស៊ីន នៅក្នុងឯកសារខ្មែរ ឬឯកសារយួននៃសតវត្សមុនៗទេយើងមិនអាចកំណត់ថាការពន្យល់បែបនេះនឹងមានតម្លៃជាស្ថាពរបានឡើយ។

**២. ការពន្យល់របស់ពួកអឺរ៉ុប :**

* តាមព្រះសង្ឃផ្សាយសាសនា Christophore Borri លោកយល់ថា តំបន់ដែលពួកព័រទុយហ្គេ ហៅនៅដើមសតវត្សទី១៧ ថាកូសាំងស៊ីននេះ មានឈ្មោះក្នុងគ្រាមភាសាជា អណ្ណាម បានន័យថា តំបន់ផ្នែកខាងលិច (នៃប្រទេសចិន)។ ឈ្មួញជប៉ុនដែលបានមករស់នៅក្នុងអណ្ណាមនោះ ក៏បានឲ្យឈ្មោះតំបន់នេះជាភាសាជប៉ុន Coci ដែលមានន័យដូចជា អណ្ណាម ដែរ។ ក្រោយមកពួកនាវិកព័ទុយហ្គេបានមកដល់ឥណ្ឌា ដែលមានឈ្មោះថា Coci (Cochin) ពួកនាវិកក៏បានបន្ថែមពាក្យ Cina (ចិន) ទៅលើឈ្មោះ Coci ៖'Coci+Cina=Cocincin (Cocina de la Chine)។

* តាមព្រះសង្ឃ Bouillevaux ដែលបានមកផ្សាយសាសនានៅឧបទ្វីបឥណ្ឌូចិន នៅចុងសតវត្សទី១៩ លោកយល់ថា ពាក្យកូសាំងស៊ីនក្រោម (Basse Cochine) ព្រោះតំបន់នេះជាដីសណ្តទាបៗ។ ប៉ុន្តែបើតាមលោក George Coedès ប្រវត្តិវិទូបារាំង បានឲ្យដឹងថាចិនក៏បានហៅប្រទេសចាម្ប៉ាថា Lin Yi ឬ Houan wang ដែរ។ ចំណែកឯយួនវិញបានហៅចាម្ប៉ាថា Chiem Thanh ។

* តាមលោក Léonard Aurousseau បានឲ្យដឹងថា នៅស.វ.ទី១៣ ដល់ស.វ.ទី១៦ ភូមិវិទូអារ៉ាប់បានចែកឆ្នេរសមុទ្រអាស៊ីខាងកើតជាភូមិភាគពីរ៖

- តំបន់ CIN (ចិន) ចាប់តាំងពីច្រោយម៉ាល្លាកា (Malacca) រហូតទៅដល់កោះ ហៃ ណាំ ដោយគិតបញ្ចូលទាំងឧបទ្វីឥណ្ឌូចិន និង Insulinde។
- តំបន់ MACIN (Grande Chine ou Chine propre) គឺតួប្រទេសចិន (ចាប់ពីកោះ ហៃ ណាំ ទៅខាងជើង) ។

គួរបញ្ជាក់ដែរថា មុនមានដំណើររបកគំហើញដីថ្មីនៅស.វ.ទី១៥-១៦ ដោយជនជាតិអឺរ៉ុប ជំនួញរវាងទ្វីបនិងប្រទេសនៅចុងបូព៌ា ធ្វើឡើងតាមរយៈពួកអារ៉ាប់តែប៉ុណ្ណោះ។

ដូចនេះដើម្បីបញ្ជាក់ទីតាំងភូមិសាស្ត្រនៃតំបន់នីមួយៗក្នុងភូមិភាគCINឲ្យបានច្បាស់ប្រាកដពួកនាវិកអារ៉ាប់ប្រហែលជាបានបន្ថែមពាក្យ CIN នេះទៅលើឈ្មោះជាគ្រាមភាសានៃតំបន់នោះទៀត។ បើតាមការពន្យល់នេះពាក្យ កូសាំងស៊ីន ដែលជាឈ្មោះនៃតំបន់ អណ្ណាម ប្រហែលអាចកើតមកពីពាក្យ ៖ KAWCI (Kiao – Tché) + Cin = Kawci de Cin (Kiao – Tché de Chine) ។ ពាក្យ KAWCI គឺជាពាក្យចិនហៅសំដៅទៅលើតំបន់អណ្ណាម។

ពួកអារ៉ាប់បានរក្សាឈ្មោះនេះរហូតមកដល់ស.វ.ទី១៥។ នៅដើមស.វ.ទី១៦ ពួកព័រទុយហ្គេបានមកដល់អាស៊ីចុងបូព៌ា ហើយប្រហែលជាប្រើពាក្យនេះដដែល (Cochinchina) សម្រាប់ហៅអណ្ណាម។

ម្យ៉ាងទៀត នៅឥណ្ឌាមានកំពង់ផែមួយឈ្មោះ Cochin (KOCI) ដែរ។ ដើម្បីកុំឲ្យច្រឡំ KOCI និង KAWCI ពួកអារ៉ាប់និងជនជាតិអឺរ៉ុបត្រូវតែបន្ថែមពាក្យ Cin នេះសម្រាប់សម្គាល់កំពង់ផែ KOCI de l'Inde ពីតំបន់ KAWCI de Cin។

## នឹកយុទ្ធជនផង

(បទពាក្យ៧)

គ្រាដែលលោកអ្នកចូលសម្រាន្ត
លើគ្រែក្បៀមក្សាន្តពូកខ្នល់ខ្នើយ
សួនព័ទ្ធវិមានក្លិនល្ហែងល្ហើយ
អ្នកអើយកុំភ្លេចគុណកងទ័ព។
កូនចៅស្រីប្រុសបានសិក្សា
លោកអ្នកត្រូវការបង្កើនទ្រព្យ
មិនគឺត្រូវមានសណ្ដាប់ធ្នាប់
សន្តិជាប់លាប់រក្សាទុន។
ជីវិតលោកអ្នកស្រស់ភ្ញុំផាន
ក្នុងលំនៅឋានសំបូរធន
តើកម្លាំងអ្នកឬយុទ្ធជន
លះបង់ជីពជន្មការពារឲ្យ។

## ន័យជីវិត

(បទពាក្យ៧)

ជីវិតរាល់រូបត្រូវការរស់
ជីវិតបាត់ឈ្មោះកេរ្តិ៍គង់នៅ
ជីវិតសត្វលោកយោគការត្រូវ
ជីវិតជាផ្លូវត្រូវកសាង។
ជីវិតរស់នៅត្រូវតស៊ូ
ជីវិតគំរូគ្រប់បែបយ៉ាង
ជីវិតរុងរឿងរស់ភ្លឺស្វាង
ជីវិតសម្អាងសាងអង់អាច។
ជីវិតអាប់អោនសូន្យវិចារណ៍
ជីវិតឧបមាដូចបិសាច
ជីវិតលះបង់ភ្លឺចិញ្ចាច
ជីវិតមិនខ្លាចខ្មាំងសត្រូវ។
ជីវិតដូចពេជ្រលេចលើថ្ម
ជីវិតបវរពិតពេកក្រូវ
ជីវិតកសាងស្វាងដើរទៅ
ជីវិតកុំនៅងាកថយក្រោយ។
ជីវិតគិតសព្វស្អប់សត្រូវ
ជីវិតរុលទៅឲ្យដល់ត្រើយ
ជីវិតសាងជាតិឃ្លាតទុក្ខស្បើយ
ជីវិតហ្នឹងហើយហៅជីវិត។
ជីវិតយំសើចសើចទាំងទុក្ខ
ជីវិតគគ្រុកលក់គំនិត
ជីវិតរស់នៅក្រៅហ្វូងមិត្ត
ជីវិតឥតបិតអ្វីក្នុងលោក។

## រឿងគំនិតខាងវៃ

ថ្ងៃមួយ មន្ត្រីអន្ទើសម្នាក់មកលេងផ្ទះអ្នកនៅក្រោមឱវាទ ចៃដន្យចំពេលកំពុងហូបបាយ។ ម្ចាស់ផ្ទះអញ្ជើញភ្ញៀវចូលរួមដោយសុទ្ធចិត្ត។ ភ្ញៀវហូបបាយអស់មួយចាន ដោយកំពុងចាប់មាត់នឹងសម្លម្ជូរគ្រឿងសាច់មាន់ស្លឹកថ្នឹង មិនឃើញម្ចាស់ផ្ទះថែមបាយឲ្យទៀតក៏និយាយចៅវ៉ៅទៅកាន់ភរិយាម្ចាស់ផ្ទះ ទាំងផ្ទៀងចានបង្ហាញផងថា៖

- សុំទោសចុះអ្នក! ចាននេះកាលទិញមកថ្លៃប៉ុន្មានដែរ?

ប្រពន្ធម្ចាស់ផ្ទះញញឹម រួចឆ្លើយតបយ៉ាងផ្អែម ទាំងផ្ទៀងឆ្នាំងទទេបង្ហាញផងថា៖

- ចាំលោក! ទិញមកដំណាលគ្នានឹងឆ្នាំងនេះ។

ភ្ញៀវ៖ ?!

## រឿងការគួរសមមួយបែប

គ្រាមួយនោះ មាននារីស្រស់សោភាម្នាក់យួរចង្ហាន់ទៅប្រគេនលោកគ្រូសង្ក្រាជឯវត្ត។ ក្រោយពេលឡើងដល់លើកុដិមាណវីបត់ជើងថ្វាយបង្គំលោកដោយខំបត់ចុងដៃបង្ហាញចិញ្ចៀនពេជ្រដេញពន្លឺថ្ងៃផ្លេកៗ ទាំងពោលថា៖

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំលោកបង!

លោកគ្រូសង្ក្រាជរៀចមាត់ទៅម្ខាងដើម្បីបង្ហាញធ្មេញមាសទើបនឹងដាក់ថ្មីៗភ្លឺឲ្យទន្ទេងជាមួយសង្ឃដីកាយ៉ាងគ្រលតបទៅវិញថា៖

- ចម្រើនពរញោម!

អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## យើងគួរចងចាំទាំងអស់គ្នា៖

ព្រះរាជាណាចក្រកម្ពុជាមាន៖

| | | | | | |
|---|---|---|---|---|---|
| - ២៥ | រាជធានី-ខេត្ត | - ៨២ | ច្រកទ្វារ៖ | | |
| - ២៧ | ក្រុង | | + | អាកាសយានដ្ឋានអន្តរជាតិ | ០៣ |
| - ១៦២ | ស្រុក | | + | ច្រកទ្វារព្រំដែនអន្តរជាតិ | ២៦ |
| - ១៤ | ខណ្ឌ | | + | កំពង់ផែ | ០៣ |
| - ១៤០៥ | ឃុំ | | + | ច្រកទ្វារទ្វេភាគី | ១៤ |
| - ២៤១ | សង្កាត់ | | + | ច្រកទ្វារព្រំដែន | ២៦ |
| - ១៤៣៨៤ | ភូមិ | | + | ច្រកទ្វារកំពង់ផែសមុទ្រ | ១០ |

ប្រភពក្រសួងមហាផ្ទៃ

# បង្កងទឹកសាបអូស្រ្តាលី

**ដកស្រង់ និងរៀបរៀងដោយ:**

លោក **នាង សារុឌ្ឍឌី** អនុប្រធានការិយាល័យវារីវប្បកម្មទឹកសាប នៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម

**សហការផ្តល់យោបល់ដោយ:**

លោក **រស់ គន្ធី** ប្រធានការិយាល័យវារីវប្បកម្មទឹកសាប នៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម

**ត្រួតពិនិត្យ និងកែសម្រួលដោយ:**

ឯកឧត្តម **ឡុង ឈាង** ទីប្រឹក្សាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ឯកឧត្តម **អេង ជាសាន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

លោក **ថាយ សុមុនី** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

## ១. លក្ខណៈជីវសាស្រ្ត

ជាប្រភេទបង្កងទឹកសាប មានទម្រង់ដូចបង្កងប៉ាក មានដង្កៀបស្រឡូន និងមានពណ៌ក្រហមនៅផ្នែកខាងចុងដង្កៀបចំពោះបង្កងឈ្មោល ។មានសំបកពណ៌បៃតងចាស់ និងមានទម្ងន់អតិបរមា ៥០០ក្រាម ចំពោះបង្កងឈ្មោល និង ៤០០ក្រាម ចំពោះបង្កងញី។ មានឈ្មោះជាភាសាអន្តរជាតិថា Red Clew Crayfish និងមានឈ្មោះវិទ្យាសាស្រ្តថា *Cherax quadricarinatus* នៅកម្ពុជាគេនិយមហៅថា បង្កងទឹកសាបអូស្រ្តាលី។ សីតុណ្ហភាពសមស្របចន្លោះ ២៣អង្សាសេ ទៅ ៣១អង្សាសេ pH ចន្លោះពី ៦.៥ ទៅ ៨.0 ភាពរឹងសរុបនៃទឹកគួរខ្ពស់ជាង ៤0ppm និងមិនលើសពី ១២0ppm កំហាប់អំបិលគួរទាបជាង ៥ភាគពាន់ ជាតិដែក និងម៉ង់កាណែស គួរទាបជាង 0.១ មីល្លីក្រាមក្នុងមួយលីត្រទឹក។ បង្កងទឹកសាបអូស្រ្តាលីនេះអាចរស់នៅបានក្នុងស្រះដីធម្មតា វាលស្រែ និងអាងស៊ីម៉ង់ត៍។ វាបន្តពូជតាមបែបធម្មជាតិដោយមិនចាំបាច់ប្រើអរម៉ូនសិប្បនិម្មិតជួយជម្រុញឡើយ វាមានពងនៅត្រង់ពោះ និងញាស់ជាកូននៅតោងជាប់ពោះមេ ប្រៀបដូចសត្វក្តាមដូច្នេះដែរ ដែលខុសពីពូជបង្កងទឹកសាបធម្មតានៅក្នុងស្រុក។ជាសត្វស៊ីចំណីនៅស្រទាប់បាត និងចូលចិត្តរស់នៅលាក់ខ្លួនក្នុងសំបុកឬទីងងឹត វាអាចរស់នៅលើគោកតែមានសីតុណ្ហសមស្របរហូតដល់ ៣0ម៉ោង។



រូបទី១: បង្កងទឹកសាបអូស្រ្តាលី ចិញ្ចឹមនៅបាត់ដំបង

## ២.ការចញ្ចឹម

ចំពោះស្រះដីអាចមានទំហំចាប់ពី ១០០ម៉ែត្រការ៉េ ដល់ ៥០០០ម៉ែត្រការ៉េ និងមានជម្រៅ ១ម៉ែត្រទៅ ២ម៉ែត្រដោយដាក់ក្នុងដង់ស៊ីតេ៥ទៅ១៥ក្បាលក្នុង១ម៉ែត្រការ៉េ កូនបង្កងពូជគួរមានទំហំ៥ក្រាមទៅ១០ក្រាមក្នុងមួយក្បាល។ វាជាប្រភេទស៊ីសាច់គ្នាជាអាហារ ដូច្នេះ ការដាក់ចិញ្ចឹមត្រូវតែមានទំហំប៉ុនៗគ្នា និងត្រូវតាមដានចាប់យកចេញបើសិនជាវាស្ទុះឆាប់ធំជាងគេ ឬក៏តូចក្រធំជាងគេ ចៀសវាងវាស៊ីគ្នាជាអាហារ។

ចំពោះការចិញ្ចឹមក្នុងអាងស៊ីម៉ង់ត៍ ឬអាងប្លាស្ទិច ត្រូវគ្រប់គ្រងតាមដានការផ្ដល់ចំណីឱ្យបានល្អ ព្រោះការចិញ្ចឹមក្នុងអាងមិនមានសារធាតុសរីរាង្គរលួយ ឬពពួកមីក្រុបផ្សេងៗជាចំណីបង្កងនៅបាតអាងដូចស្រះដីឡើយ ហេតុនេះបង្កងអាចស៊ីគ្នាជាអាហារ ធ្វើឱ្យអត្រារស់ទាបជាងស្រះដី។




រូបទី២: ការចិញ្ចឹមបង្កងទឹកសាបអូស្ត្រាលីក្នុងស្រះ និងក្នុងអាងស៊ីម៉ង់ត៍ លក្ខណៈគ្រួសារនៅបាត់ដំបង

## ៣.ចំណី

-ចំណីធម្មជាតិ : រួមាន កំពឹស សាច់ខ្យង សាច់ដូងខ្ចី ចេកទុំ ស្វាយទុំ សារាយ ស្មៅ គ្រាប់ស្រូវ និងស្លឹកឆ័ត្រជាដើម។ល។

-ចំណីគ្រាប់ : ចំណីគ្រាប់សម្រាប់បង្កងប្រភេទនេះមានទំហំប្រមាណ១មល្លីម៉ែត្រ និងមានកម្រិតប្រូតេអ៊ីនចាប់ពី ២៥% ឡើងទៅ និងមានកម្រិតលីពីត ៨% ។

ផ្តល់ចំណីតែមួយដងក្នុងមួយថ្ងៃ នៅចន្លោះម៉ោង៤ទៅម៉ោង៥ល្ងាច។ រយៈពេលចិញ្ចឹមចាប់ពី ៦ ទៅ៨ខែ អាចបានទម្ងន់ប្រមាណជាង១០០ក្រាមក្នុងមួយក្បាល។ការចិញ្ចឹមអាចពន្យាពេលដល់១៥ខែទៅតាមទំហំនៃតម្រូវការទីផ្សារ។



រូបទី៣: ចំណីគ្រាប់ សម្រាប់បង្កងទឹកសាបអូស្ត្រាលី

## ៤.ការដឹកជញ្ជូន

គេអាចដឹកជញ្ជូនកូនបង្កងពូជ បង្កងមេបា ឬ បង្កងសាច់តាមវិធីសាស្ត្រសួតតែសើម គឺគេអាចប្រើប្រអប់ជ័រ ឬស្នោ ដាក់សារាយសើម ឬមានទឹកកកម៉ត់បន្តិចចូលក្នុងប្រអប់ រួចផ្ទុកក្នុងដង់ស៊ីតេសមល្មមចៀសវាងការគរលើគ្នាច្រើនពេក (មើលរូបទី៤) ហើយប្រអប់ស្នោត្រូវចោះរន្ធពីលើដើម្បីឱ្យមានខ្យល់ចូល។ ការដឹកជញ្ជូនរបៀបនេះបង្កងអាចរស់នៅបានប្រមាណ ៣០ម៉ោង។




រូបទី៤: ការដឹកជញ្ជូនដោយប្រើប្រអប់ស្នោ

## ៤.ការបង្កាត់ពូជ

ចំពោះបច្ចេកទេសក្នុងការបង្កាត់ភ្ញាស់គឺកសិករអាចធ្វើការបង្កាត់ភ្ញាស់ពេញមួយឆ្នាំ ដោយដាក់បង្កាត់មេបាពូជដែលមានអាយុចាប់ពី៤ខែឡើងទៅ និងមានទម្ងន់ប្រប្រហែល ១០០ក្រាម ដោយដាក់សមាមាត្រញីមួយ ឈ្មោលមួយ ក្នុងរយៈពេលចាប់ពី៣៥-៤០ថ្ងៃ ទើបទទួលបានកូនបង្កងពូជ។ មេពូជ១ក្បាលផលិតពង

ចាប់ពី ៣០០-៥០០ពង ឬច្រើនជាងនេះអាស្រ័យលើទំហំរបស់មេពូជ។ តាមបទពិសោធន៍កសិករ ការផលិតតាមបែបធម្មជាតិនេះ គាត់អាចប្រមូលកូនបង្កងរាល់៤០ថ្ងៃម្តង ដោយប្រើប្រាស់មេបា៣០០ក្បាល ទទួលមានកូនបង្កងពូជចំនួន ២០០០កូន។

ការបង្កាត់ពូជអាចធ្វើបានគ្រប់រដូវ ការផលិតរបស់កសិករសព្វថ្ងៃគឺតាមបែបធម្មជាតិសុទ្ធសាធ ដោយប្រើតែប្រព័ន្ធទឹកបាញ់ស្រោច និងដុំខ្យល់ដើម្បីបង្កើនអុកស៊ីសែនតែប៉ុណ្ណោះ។

ការធ្វើវារីវប្បកម្មចំពោះបង្កងទឹកសាបនេះកំពុងអនុវត្តជាលក្ខណៈគ្រួសារ និងស្ថិតក្នុងលក្ខណៈស្រាវជ្រាវនៅឡើយ។ ហើយកសិករកំពុងផ្តោតយ៉ាងសំខាន់ទៅលើការបង្កាត់ ភ្ញាស់ពូជ ជាងការចិញ្ចឹម ព្រោះតម្រូវការកូនបង្កងពូជកំពុងមានតម្រូវការខ្ពស់ពីអ្នកចិញ្ចឹម ជាពិសេស ប្រើរយៈពេលខ្លីជាងការចិញ្ចឹមយកសាច់។

ជាមួយគ្នានេះដែរ កសិករកំពុងធ្វើការសិក្សាស្រាវជ្រាវបន្តនិងពង្រីកទីផ្សារលក់កូនបង្កងពូជនិងបង្កងសាច់ ទាំងនៅក្នុងស្រុក និងទៅបណ្តាលខេត្តនានា ដូចជា កសិករមកពីខេត្តកំពង់ធំ សៀមរាប ស្វាយរៀង ខេត្តព្រះសីហនុនិងរាជធានីភ្នំពេញ។ល។ដោយធ្វើការផ្សព្វផ្សាយតាមរយៈការបង្កើតជានាមប័ណ្ណព្រមទាំងប្រព័ន្ធអនឡាញ ( Facebook Page ) និងតាមរយៈកសិករចិញ្ចឹមដូចគ្នាផងដែ។តម្លៃកូនកូនបង្កងចាប់ពី ៥០០រៀលដល់ ១៥០០រៀល។




រូបទី៥: អាងបង្កាត់ពូជបង្កងទឹកសាបអូស្ត្រាលី

## ៥.ជំងឺដែលធ្លាប់ជួបប្រទះ

- ជំងឺ រីកេតស្យា ( Systematic Rickettsia )

ជំងឺរីកេតស្យា បង្កឡើងដោយភ្នាក់ងារបង្កជំងឺឈ្មោះ Rickettsia - like organism វាជាពពួកបាក់តេរី។ រោគសញ្ញានៃជំងឺមានដូចជា មានសកម្មភាពយឺតយ៉ាវ មិនចង់ស៊ីចំណី ធំធាត់យឺត និងមានអត្រាងាប់ខ្ពស់។

- ជំងឺ ស កន្ទុយ ( White Tail )

ជំងឺ ស កន្ទុយ បង្កឡើងដោយភ្នាក់ងារបង្កជំងឺឈ្មោះ Thelohania និងមួយចំនួនផ្សេងទៀត វាជាពពួកផ្សិត Microsporidia ។ រោគសញ្ញានៃជំងឺមានដូចជា មានភាពក្រិន និងពណ៌ស្រអាប់នៅសាច់ដុំត្រង់ពោះ វាមិនសូវកើតមានច្រើនទេ តែបើកើតហើយនឹងមានអត្រាងាប់ខ្ពស់៕


ឯកសារយោង:

1. https://thefishsite.com
2. https://www.dpi.nsw.gov.au
3. www.theaquariumwiki.com
4. https://vfa.vic.gov.au
5. crayfishblue.weebly.com>life-cycle
6. https://www.amazon.com
7. https:www.cabi.org>isc>datasheet


រូបភាព: កសិករចិញ្ចឹមបង្កងទឹកសាបអូស្ត្រាលី នៅខេត្តបាត់ដំបង ឆ្នាំ ២០១៩

សម្ភាសន៍បទពិសោធន៍:

១. លោក តាំង លាងឆាយ អាយុ ២៣ឆ្នាំ ០៦៩ ៥០៤ ៧២៣ ០៩៥ ៣៣៣៤៨៣
២. លោក ហៀច សុភ័ក្រ្ត អាយុ ៣៥ ឆ្នាំ ០១២ ៨២៨ ៣៥៨
៣. លោក ចៅ សំណុល ០១២ ៩៦៣ ០០២
៤. លោក បាន មី ( ឪពុកលោក ផល រដ្ឋា ) ០៩៧ ៩៦៥ ៧៧២៥

# ប្រវត្តិការងារ
# សពឯកឧត្តម សូវ ជីវគុណ
# អតីតសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



ឯកឧត្តម **សូវ ជីវគុណ** កើតនៅក្នុងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៥០ នៅភូមិជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានឪពុកឈ្មោះ **សូវ ឡេង** និងម្តាយឈ្មោះ **អ៊ឹង សៀប**។ ឯកឧត្តម មានបងប្អូនបង្កើតចំនួន ៦នាក់ ដោយក្នុងនោះ ឯកឧត្តមជាកូនទី២ក្នុងគ្រួសារ។ ឯកឧត្តមមានភរិយា ឈ្មោះ **ព្រំ សារូ** អ្នកទាំងពីរទទួលបានចំណងដៃកូនស្រីពីរនាក់ ដោយកូនទី១ ឈ្មោះ **សូវសូរិយា** និងកូនទី២ឈ្មោះ **សូវសុធិតា**។ នៅក្នុងវ័យសិក្សា ឯកឧត្តម បានសិក្សានៅវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត។ បន្ទាប់មកទៀតនៅឆ្នាំ១៩៧០ឯកឧត្តមបានចូលបម្រើការងារជាមន្ត្រីនៅនាយកដ្ឋានភូគព្ភសាស្ត្ររ៉ែ និងប្រេងកាត ក្រសួងឧស្សាហកម្ម ហើយនៅឆ្នាំ១៩៧២ ឯកឧត្តម បានក្លាយជានាយកមន្ទីរនីតិកម្ម ត្រួតពិនិត្យ និងអាជីវកម្មរ៉ែ។ ក្រោយថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ប៉ុល ពត ឯកឧត្តម ជាបុគ្គលិកនៅមន្ទីរឧស្សាហកម្មរាជធានីភ្នំពេញ ហើយបានឡើងតួនាទីជាបន្តបន្ទាប់រហូតដល់មានឋានៈជាអគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅឆ្នាំ១៩៩៩។ ចាប់ពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៥ ឯកឧត្តម **សូវ ជីវគុណ** ជាសមាជិក ឋានៈស្មើអនុរដ្ឋលេខាធិការ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) និងត្រូវបានដំឡើងឋានៈស្មើរដ្ឋលេខាធិការ នៅឆ្នាំ២០១៨។

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានក្តីក្តុកក្តួល ខ្សឹកខ្សួល និងទុក្ខក្រៀមក្រំបំផុតចំពោះមរណភាពរបស់ ឯកឧត្តម **សូវ ជីវគុណ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កាលពីថ្ងៃចន្ទ ទី១ ខែមិថុនា ឆ្នាំ២០២០ ក្នុងជន្មាយុ៧៥ឆ្នាំ ដោយរោគាពាធ។

នាឱកាសដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សូមចូលរួមរំលែកទុក្ខ និងសេចក្តីសោកសង្រេក ព្រមទាំងការសោកស្តាយ អាឡោះអាល័យជាមួយលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ ឯកឧត្តម **សូវ ជីវគុណ** ជាទីគោរពស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ និងទឹកចិត្តប្រណី សន្តោសចំពោះបុត្រនិងភរិយា។

ការបាត់បង់ ឯកឧត្តម **សូវ ជីវគុណ** គឺជាការបាត់បង់កុលបុត្រឆ្នើមមួយរូបដែលបានបូជាអស់ពីកម្លាំងកាយ បញ្ញា និងស្មារតី បានបំពេញការងារដោយការទទួលខុសត្រូវខ្ពស់ក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម-កិច្ច និងវប្បធម៌ ដើម្បីរួមចំណែកក្នុងការការពារជាតិ និងការអភិវឌ្ឍប្រទេស។

យើងខ្ញុំទាំងអស់គ្នា សូមបួងសួងវត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដួងវិញ្ញាណក្ខ័ន្ធរបស់ឯកឧត្តម**សូវជីវគុណ**ដើម្បីបានទៅសោយសុខក្នុងសុគតិភព ជានិរន្តរ៍តរៀងទៅ។

សូមលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ទទួលនូវមនោសញ្ចេតនាចែករំលែកទុក្ខក្រៀមក្រំអំពីយើងខ្ញុំទាំងអស់គ្នា៕



ជ្រោះប៊ូស្រា ខេត្តមណ្ឌលគីរី